ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

# THE FINANCIAL MANAGEMENT PROCESS OF ACLEDA BANK PLC.

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

# THE FINANCIAL MANAGEMENT PROCESS OF ACLEDA BANK PLC.


គ្រូណែនាំ ៖ ឯក វ៉ាន់ឌុន

ជំនាញ គណនេយ្យ



រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទៈ ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារអេស៊ីលីដា សាខាម៉ៅសេទុង**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ឯក វ៉ាន់ឌុន

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ួ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមនាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេសក្រុមនាងខ្ញុំបានយល់ច្បាស់ថា ជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរ សម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តីឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តីសុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យ ដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាពីឆ្នាំទីមួយរហូតដល់ឆ្នាំសិក្សាទីបួន។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែ មានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិត ឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្តន៍ ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័ន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយ ក្រុមនាងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះ មានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើប ក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅ ពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតធីង។ ក្រុមនាងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើងនឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀត ដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមនាងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ឡើ គន្ធី

ID: B22/1584



ឆៃ ស្រីឡែន

ID: B22/1619



ឈន ឈុនឡេង

ID: B22/425



សេង មិថុនា

ID: B22/424



គាត ជាកគីម

ID: B22/1771

# សេចក្តីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភគាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមនាងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមនាងខ្ញុំសូមសម្តែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្តាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមនាងខ្ញុំនាពេលកន្លងមក។

ក្រុមនាងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់ បទពិសោធន៍យ៉ាងច្រើនដល់នាងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ឯក វ៉ាន់ឌុន** ជាគ្រូណែនាំដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមនាងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្តាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមនាងខ្ញុំរហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមនាងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើ ឱ្យជួបតែ ពុទ្ធពរ បួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដាជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ឌឿ គន្ធី

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រោមការណែនាំ និងការលើកទឹកចិត្តពីថ្នាក់ដឹកនាំនៃ សាកលវិទ្យាល័យវ៉ាន់ដា បានផ្តល់ឱកាសយ៉ាងជ្រាលជ្រៅសម្រាប់ក្រុមនាងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យក្រោយប្រធានបទ **ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាម៉ៅសេទុង** អត្ថបទនេះត្រូវបានសរសេរក្នុងគោលបំណងសិក្សាស្វែងយល់ពីប្រវត្តិរបស់ធនាគារ ស្ថានភាពទូទៅ ចក្ខុវិស័យ បេសកកម្មនៃដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុកំណត់បញ្ហាប្រឈម ដែលធនាគារប្រឈមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍សម្រាប់កែលម្អដំណើរការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ ផែនការក្នុងគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ចំពោះការពង្រឹងសមត្ថភាពគ្រប់គ្រង និងការបង្កើនស្ថិរភាពនៅក្នុងស្ថាប័ន តាមរយៈផែនការ។ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ លើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការប្រើប្រាស់ បច្ចេកវិទ្យា (FinTech) និងប្រព័ន្ធ MIS ធនាគារ អេស៊ីលីដា បានអនុវត្តន៍បច្ចេកវិទ្យាទំនើប ដើម្បីបង្កើន ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ចំណាយ និងចំណូល ដោយធានាថាបានរក្សានូវភាពច្បាស់លាស់ និងសុវត្ថិភាពលើទិន្នន័យ។ ថែមទាំងរក្សាទំនាក់ទំនងល្អជាមួយអតិថិជន ការពង្រឹងសមត្ថភាពប្រតិបត្តិការ ប្រើប្រាស់ប្រព័ន្ធទំនើប គ្រប់គ្រងចំណុចងាយខូចខាត និងទប់ស្កាត់ហានិភ័យហិរញ្ញវត្ថុ។ សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុនៅធនាគារ អេស៊ីលីដា ដើម្បីធានាបាននូវស្ថិរភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ស្ថាប័ន។ ការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវបានបង្ហាញពីស្ថានភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ រួមមានចំណូល ចំណាយ ការគ្រប់គ្រងហិរញ្ញវត្ថុ ហើយបានបង្ហាញតួនាទីសំខាន់នៃការច្នៃប្រឌិតឧបករណ៍ FinTech និងប្រព័ន្ធព័ត៌មានគ្រប់គ្រង (MIS) ក្នុងការកែលម្អប្រសិទ្ធភាពប្រតិបត្តិការនានា។ ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពអាចជួយបង្កើនស្ថិរភាព និងបង្កើនប្រតិបត្តិការរបស់ធនាគារ។ ការប្រើប្រាស់ព័ត៌មានជាក់ស្តែង និងប្រព័ន្ធ MIS មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការរក្សាសមត្ថភាពអង្គភាពហិរញ្ញវត្ថុ។ ទោះបីជាមានបញ្ហាប្រឈមខ្លះៗ ស្ថិតនៅក្នុងដំណើរការគ្រប់គ្រងយ៉ាងណាក៏ដោយ ក៏អាចត្រូវបានដោះស្រាយតាមរយៈការផ្តល់បណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញថ្មីៗសម្រាប់បុគ្គលិក និងបណ្តុះបណ្តាលឱ្យបុគ្គលិកប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ ចុងក្រោយនេះ ការសិក្សាស្រាវជ្រាវបានផ្តល់អនុសាសន៍ ពីតម្រូវការកែលម្អប្រព័ន្ធគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព ដោយផ្តោតសំខាន់ទៅលើបុគ្គលិក បច្ចេកវិទ្យា និងការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុឱ្យត្រឹមត្រូវ។ ទាំងនេះជាជំហានសំខាន់ណាស់សម្រាប់ធនាគារ អេស៊ីលីដា ក្នុងការគ្រប់គ្រងឯកសារហិរញ្ញវត្ថុ និងធានាជោគជ័យផ្នែកសេដ្ឋកិច្ចនាពេលអនាគត។

# មាតិកា

ទំព័រ

អារម្ភកថា ........ ii
រចនាសម្ព័ន្ធក្រុម ........ ii
សេចក្ដីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១

## សេចក្ដីផ្ដើម

១.១លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១.តើធនាគារអេស៊ីលីដាមានផែនការដូចម្ដេច ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព?
២.តើការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព មានសារៈសំខាន់អ្វីខ្លះសម្រាប់ធនាគារអេស៊ីលីដា?
១.៣គោលបំណងនៃការស្រាវជ្រាវ ........ ១
១.៤ទំហំដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៦សារៈសំខាន់នៃការស្រាវជ្រាវ ........ ២
១.៦.១ សារៈសំខាន់នៃការស្រាវជ្រាវចំពោះក្រុមស្រាវជ្រាវផ្ទាល់ ........ ២
១.៦.២ សារៈសំខាន់នៃការស្រាវជ្រាវចំពោះស្ថាប័ន ........ ៣
១.៦.៣ សារៈសំខាន់នៃការស្រាវជ្រាវចំពោះសង្គម ........ ៣
១.៧រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២

## ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ ........ ៤
២.១.១និយមន័យការគ្រប់គ្រង ........ ៤
២.១.២ប្រវត្តិនៃការគ្រប់គ្រង ........ ៤

២.២ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ ........ ៦
២.២.១និយមន័យហិរញ្ញវត្ថុ ........ ៦
២.២.២ប្រវត្តិហិរញ្ញវត្ថុ ........ ៦
២.២.៣ទ្រឹស្តីពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ........ ៧
២.៣ ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ ........ ៧
២.៣.១ និយមន័យធនាគារ ........ ៧
២.៣.២ ប្រវត្តិនៃធនាគារ ........ ៨
២.៣.៣ ទ្រឹស្តីពាក់ព័ន្ធនឹងធនាគារ ........ ៨

## ជំពូកទី៣

## ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា សាខាម៉ៅសេទុង

៣.១ ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីដា ........ ៩
៣.១.១ ប្រវត្តិរបស់ធនាគារ អេស៊ីលីដា ........ ៩
៣.១.២ បេសកកម្ម ទស្សនវិស័យ របស់ធនាគារ អេស៊ីលីដា ........ ១០
ក.បេសកកម្ម ........ ១០
ខ.ទស្សនវិស័យ ........ ១០
៣.១.៣ ទីតាំង និងសាខារបស់ធនាគារ អេស៊ីលីដា ........ ១០
៣.១.៤ ស្លាកសញ្ញា អត្ថន័យ និងគុណតម្លៃរបស់ធនាគារ អេស៊ីលីដា ........ ១១
៣.១.៥ សមាសភាពរបស់ក្រុមប្រឹក្សាភិបាល និងអភិបាល ........ ១២
៣.២ ផែនការ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពរបស់ធនាគារអេស៊ីលីដា ........ ១៧
៣.២.១ ការរៀបចំផែនការគ្រប់គ្រងហិរញ្ញវត្ថុ ........ ១៧
ក. ការកំណត់ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារអេស៊ីលីដា ........ ១៧
ខ. ការរៀបចំគម្រោងផែនការថវិការបស់ធនាគារ អេស៊ីលីដា ........ ១៨
គ.ផែនការប្រើប្រាស់ឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ........ ២០
ឃ. ការវាយតម្លៃប្រាក់ចំណូលដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ........ ២១
ង. វាយតម្លៃចំណាយដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ........ ២១
ច. ផែនការនៃការព្យាករណ៍ពីលំហូរសាច់ប្រាក់ (Cash Flow Forecast)របស់ធនាគារ អេស៊ីលីដា ........ ២២
ឆ. ការគ្រប់គ្រងបំណុល និងទុនអាជីវកម្មរបស់ធនាគារ អេស៊ីលីដា ........ ២២
ជ. ការត្រួតពិនិត្យ និងវាយតម្លៃការរៀបចំរបាយការណ៍ប្រចាំខែ/ត្រីមាសរបស់ធនាគារ អេស៊ីលីដា ........ ២៤
៣.៣ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពមានសារៈសំខាន់សម្រាប់ធនាគារ អេស៊ីលីដា ........ ២៤
៣.៣.១ ធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ ........ ២៤
៣.៣.២ ការធ្វើផែនការរបស់ធនាគារ អេស៊ីលីដា (ACLEDA Bank) ........ ២៥

៣.៣.៣ការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុរបស់ធនាគារអេស៊ីលីដា.................................. ២៦
៣.៣.៤ សម្រេចផែនការ និងអនុវត្តគោលនយោបាយល្អ របស់ធនាគារ អេស៊ីលីដា............. ២៧

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំងរបស់ធនាគារ អេស៊ីលីដា........................................................២៩
៤.២ការវិភាគលើចំណុចខ្សោយរបស់ធនាគារអេស៊ីលីដា ......................................................២៩

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ..........................................................................................................៣០
៥.២ ការផ្តល់អនុសាសន៍ .....................................................................................................៣១
**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍លើគ្រប់វិស័យ ដែលវិស័យទាំងនោះបានជំរុញសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន តាមរយៈការបង្កើតការងារជូនប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយភាពក្រីក្រ និងភាពគ្មានការងារដែលជាហេតុនាំឱ្យមានការធ្វើចំណាកស្រុកជាដើម។ រដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការទាក់ទាញអ្នកវិនិយោគគ្រប់វិស័យមកបណ្ដាក់ទុននៅក្នុងប្រទេសកម្ពុជាមាន ដូចជាវិស័យឧស្សាហកម្ម វិស័យកសិកម្ម វិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យសំណង់ និងអចលនទ្រព្យ ជាពិសេស វិស័យធនាគារ និងហិរញ្ញវត្ថុឱ្យកាត់តែមានភាពរីកចម្រើនខ្លាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ការគ្រប់គ្រងហិរញ្ញវត្ថុ ជាផ្នែកសំខាន់មួយសម្រាប់ការអភិវឌ្ឍវិស័យធនាគារ ដោយមានការប្រកួតប្រជែងយ៉ាងខ្លាំង ទាំងក្នុងចំណោមធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ស្ថាប័នទាំងនេះបានខិតខំរៀបចំផែនការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព ដើម្បីបង្កើនទំនុកចិត្តពីអតិថិជន ក្នុងការជ្រើសរើសសេវាកម្មរបស់ខ្លួន។ ការគ្រប់គ្រងហិរញ្ញវត្ថុមានសារៈសំខាន់យ៉ាងខ្លាំង ពីព្រោះវាជាចលករមួយដ៏មានប្រសិទ្ធិភាពក្នុងការជម្រុញសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាមួយនឹងការរីកចម្រើនយូរអង្វែងនៃវិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបាននាំឱ្យវិស័យហិរញ្ញវត្ថុទាំងមូលមានការរីកលូតលាស់ និងទទួលបានជោគជ័យបន្តបន្ទាប់។

ដើម្បីឱ្យធនាគារមួយ មានការរីកចម្រើនទៅបានជាចាំបាច់ណាស់គួរតែការអនុវត្តនូវផែនការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានល្អ ឬវិធីសាស្ត្រផ្សេងៗក្នុងការគ្រប់គ្រងអាជីវកម្មរបស់ខ្លួនឱ្យបានល្អ។ ដូច្នេះហើយ ទើបធនាគារ អេស៊ីលីដា ប្រកាន់ភ្ជាប់នឹងបានអនុវត្តន៍ផែនការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនឱ្យបានល្អ ក្នុងការធ្វើឱ្យមានភាពរីកចម្រើនចាប់តាំងពីកកើតរហូតដល់នាពេលបច្ចុប្បន្ន។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិត អង្គភាពទាំងអស់ចាំបាច់ណាស់ត្រូវតែយកចិត្តទុកដាក់ទៅលើ ផែនការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានល្អ ពីព្រោះការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព មានសារៈសំខាន់ដើម្បីឱ្យដំណើរការអាជីវកម្មទទួលបានប្រសិទ្ធភាព និងលទ្ធផលល្អ។ ហេតុដូច្នេះហើយ បានជានៅក្នុងប្រធានបទនេះបានលើកយកសំណួរពីរដូចខាងក្រោម មកសិក្សាស្រាវជ្រាវ និងធ្វើការបកស្រាយ៖

- តើធនាគារអេស៊ីលីដាមានផែនការដូចម្ដេច ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព?
- តើការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព មានសារៈសំខាន់អ្វីខ្លះសម្រាប់ធនាគារអេស៊ីលីដា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺផ្ដោតសំខាន់ទៅលើប្រធានបទ ដំណើរការនៃការគ្រប់គ្រង ហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺដើម្បីរួមចំណែកក្នុងការផ្ដល់យោបល់ និងផ្ដល់អនុសាសន៍លើចំណុចខ្វះខាត និងធ្វើការស្វែងយល់បន្ថែមទៀតលើចំណុចមួយចំនួនដូចខាងក្រោម៖

- យល់ដឹងអំពីដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ដើម្បីយល់ដឹងអំពីផែនការដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពរបស់ធនាគារ អេស៊ីលីដា
- យល់ដឹងអំពីសារៈសខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព
- ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

នៅក្នុងការស្រាវជ្រាវនេះ យើងបានផ្តោតសំខាន់ទៅលើ ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុដូចជាការធ្វើផែនការ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព និងសារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដាតែប៉ុណ្ណោះ។ ដំណើរការនៃការស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពី ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ដែលមានទីតាំងនៅសាខាម៉ៅសេទុង អគារលេខ ២៤៤ មហាវិថីម៉ៅសេទុង(២៤៥) ភូមិ៣ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទនេះ គឺបានធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារយោងឆ្នាំ២០២៣។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទដែលបានលើកមកធ្វើការស្រាវជ្រាវនេះ គឺតាមបែបវិធីសាស្ត្រគុណវិស័យដោយទិន្នន័យមួយចំនួនត្រូវបានដកស្រង់ចេញពីគេហទំព័រ និងឯកសារពាក់ព័ន្ធដែលទាក់ទងនឹងប្រធានបទ។ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យក្នុងការស្រាវជ្រាវនេះ តាមរយៈការសង្កេតពីដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីយកមកធ្វើការពន្យល់ពីនិយមន័យ ប្រវត្តិ ក៏ដូចជាទ្រឹស្តីពាក់ព័ន្ធ និងបកស្រាយនូវសំណួរដែលបានចោទសួរនៅក្នុងប្រធានបទជាដើម។

- **សម្រាប់សំណួរទី១៖** ប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈឯកសារដែលបានយកមកពីធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីធ្វើការបកស្រាយទៅលើផែនការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព។
- **សម្រាប់សំណួរទី២៖** ប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈឯកសារដែលបានមកពីធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីបកស្រាយទៅលើសារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីក្រុមនាងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទរួចមក ទទួលបានការយល់ដឹងបន្ថែមទៅលើផែនការសារៈសំខាន់នៃដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុដូចជា៖

### ១.៦.១ សារៈសំខាន់នៃការស្រាវជ្រាវ

#### ១.៦.១.១ ចំពោះក្រុមស្រាវជ្រាវផ្ទាល់

- យល់ដឹងពីដំណើរនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
- យល់ដឹងពីការធ្វើផែនការនៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព
- យល់ដឹងពីសារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ
- ការយល់ដឹងអំពីនីតិវិធីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

- ជួយពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយ
- យល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ធនាគារ អេស៊ីលីដា ពីដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព
- បង្កើនចំណេះដឹងបន្ថែមទាំងទ្រឹស្តី រួមទាំងអនុវត្តន៍ជាក់ស្តែង
- ទទួលនូវបទពិសោធន៍ និងចំណេះដឹងបន្ថែមទៀត ដែលផ្សារភ្ជាប់ទៅនឹងទ្រឹស្តីដែលបានសិក្សាកន្លងមក រួមទាំងការងារជាក្រុម។
- ទទួលបាននូវការសហការជាក្រុម ក្នុងការបង្កើននូវលទ្ធផលការងារឱ្យកាន់តែប្រសើរឡើង។

#### ១.៦.១.២ សារៈសំខាន់នៃការស្រាវជ្រាវចំពោះស្ថាប័ន

- ទទួលបានការអភិវឌ្ឍន៍ បន្ថែមទៅលើចំណុចខ្វះខាត
- បង្កើនភាពជឿជាក់ និងទំនុកចិត្តដល់អតិថិជន
- យល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនមកកែលម្អ និងអភិវឌ្ឍ។

#### ១.៦.១.៣ សារៈសំខាន់នៃការស្រាវជ្រាវចំពោះសង្គម

- បន្សល់ទុកឯកសារដល់និស្សិតជំនាន់ក្រោយដើម្បីសិក្សាស្រាវជ្រាវ និងយល់ដឹងបន្ថែម
- ផ្តល់ឱ្យសាធារណជននូវឯកសារស្តីអំពីដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- បង្កើនការអភិវឌ្ឍន៍លើផែនការហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយ។

### ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវទទួលបានលទ្ធផលល្អ ត្រូវចែកចេញជា៥ជំពូកធំៗគឺ៖

- **ជំពូកទី១ សេចក្តីផ្តើម៖** បានបង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់នឹងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។
- **ជំពូកទី២ រំលឹកទ្រឹស្តី៖** លក្ខណៈទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ និងផែនការគ្រប់គ្រងហិរញ្ញវត្ថុ។
- **ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ៖** ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីដា ផែនការ ដើម្បីហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពរបស់ហិរញ្ញវត្ថុធនាគារ និងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពមានសារៈសំខាន់សម្រាប់ធនាគារ អេស៊ីលីដា។
- **ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ៖** ការវិភាគចំណុចខ្លាំង និងការវិភាគចំណុចខ្សោយ។
- **ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖** សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

# ជំពូកទី២
# ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ

### ២.១.១ និយមន័យការគ្រប់គ្រង

**ការគ្រប់គ្រង** គឺជាដំណើរការធ្វើផែនការ ចាត់តាំង ដឹកនាំ និងត្រួតពិនិត្យ ទៅលើការប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀត ដើម្បីសម្រេចគោលដៅអង្គភាព[1] ។

**ការគ្រប់គ្រង** គឺជាការទទួលខុសត្រូវដ៏លំបាកមួយដែលទាមទារ ឱ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវតែមានសមត្ថភាពការយល់ដឹងខ្ពស់រហ័សរហួនប្រកបដោយភាពប៉ិនប្រសព្វនឹងមានចំណេះដឹងធំទូលាយបើទោះបីជាយ៉ាងនេះ ក៏ដោយនៅតែមានអ្នកគ្រប់គ្រងខ្លះទទួលបានជោគជ័យ ហើយខ្លះបរាជ័យផងដែរ[2]។

### ២.១.២ ប្រវត្តិនៃការគ្រប់គ្រង

គំនិតនៃការគ្រប់គ្រងមានតាំងពីរាប់ពាន់ឆ្នាំមកហើយ។ យោងតាម Pindur, Rogers, and Kim (១៩៩៥) វិធីសាស្រ្តសំខាន់ៗក្នុងការគ្រប់គ្រងបានត្រលប់មកវិញយ៉ាងហោចណាស់ ៣,០០០ ឆ្នាំមុនពេលកំណើតរបស់ព្រះគ្រិស្ត ដែលជាពេលវេលាមួយដែលកំណត់ត្រានៃការធ្វើជំនួញត្រូវបានកត់ត្រាជាលើកដំបូងដោយពួកបូជាចារ្យនៅមជ្ឈិមបូព៌ា។ សូក្រាត នៅប្រហែលឆ្នាំ៤០០ មុនគ្រឹស្តសករាជ បាននិយាយថា ការគ្រប់គ្រងគឺជាសមត្ថភាពដាច់ដោយឡែកពីជំនាញបច្ចេកទេសនឹងចំណេះដឹង ( Higgins ១៩៩១ )។ ជនជាតិរ៉ូមដែលល្បីល្បាញដោយសារកងទាហានរបស់ពួកគេដឹកនាំដោយ Centurions បានផ្តល់ការទទួលខុសត្រូវតាមរយៈឋានានុក្រមនៃសិទ្ធិអំណាច។ ព្រះវិហាររ៉ូម៉ាំងកាតូលិកត្រូវបានរៀបចំតាមបន្ទាត់នៃទឹកដីជាក់លាក់ខ្សែសង្វាក់នៃពាក្យបញ្ជានិងការពិពណ៌នាការងារ។ នៅក្នុងអំឡុងមជ្ឈិមសម័យចន្លោះឆ្នាំ ១០០០ ប្រហែលពីឆ្នាំ ៤៧៦ នៃគ.ស ដល់ ១៤៥០ គ.ស Guilds ដែលជាបណ្តុំនៃសិប្បករ និងពាណិជ្ជករបានផ្តល់ទំនិញដែលធ្វើដោយដៃចាប់ពីនំប៉័ងដល់ពាសដែក និងដាវសម្រាប់បូជនីយកិច្ច។ ឋានានុក្រមនៃការគ្រប់គ្រង និងអំណាចស្រដៀងទៅនឹងវិហារកាតូលិក ដែលជាអាជ្ញាធរបានសម្រាកជាមួយចៅហ្វាយហើយបោកបញ្ឆោតទៅកាន់អ្នកធ្វើដំណើរ និងកូនជាង។ សិប្បករទាំងនេះ គឺជាអាជីវកម្មខ្នាតតូចដែលផលិតផលដែលមានកម្រិតគុណភាពខុសៗគ្នាអត្រាផលិតភាពទាប និងតម្រូវការតិចតួចសម្រាប់ការគ្រប់គ្រងលើសពីម្ចាស់ ឬសិប្បករមេ។

បដិវត្តន៍ឧស្សាហកម្មដែលជាពេលវេលាមួយពីចុងទសវត្សរ៍ឆ្នាំ ១៧០០ ដល់ឆ្នាំ ១៨០០ គឺជារយៈពេលនៃភាពចលាចល និងការផ្លាស់ប្តូរដ៏ធំនៅក្នុងរបៀបរស់នៅ និងការងាររបស់មនុស្ស។ មុននេះ ប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែចំការ ឬធ្វើការ និងរស់នៅក្នុងសហគមន៍ជនបទ។ ជាមួយនឹងការបង្កើតម៉ាស៊ីនចំហាយទឹក ការច្នៃប្រឌិតជាច្រើនបានកើតឡើង រួមទាំងចលនាដោយស្វ័យប្រវត្តិនៃធ្យូងថ្មពីអណ្តូងរ៉ែក្រោមដី រោងចក្រថាមពលដែលឥឡូវនេះទំនិញផលិតយ៉ាងច្រើនដែលផលិតដោយដៃ និងក្បាលរថភ្លើងផ្លូវដែកដែលអាចផ្លាស់ទីផលិតផល និងសម្ភារៈឆ្លងកាត់ប្រទេសនានាៅៀបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពរោងចក្រ ត្រូវការកម្មករដែលទាមទារទិសដៅ និងអង្គការ។ ដោយសារគ្រឿងបរិក្ខារទាំងនេះកាន់តែមានសារៈ

[1] WordPress. Sokankeng (2021, June 10). *និយមន័យការគ្រប់គ្រង.* Retrieved from https://sokankeng.wordpress.com

[2] Scribd. (2021, June 10). *និយមន័យការគ្រប់គ្រង.* Retrieved from https://www.scribd.com

សំខាន់ និងផលិតភាពតម្រូវការសម្រាប់ការគ្រប់គ្រង និងការសម្របសម្រួលបានក្លាយជាកត្តាសំខាន់។ គិតអំពី Henry Fond ដែលជាបុរសដែលបានបង្កើតខ្សែដំឡើងចល័តដើម្បីផលិតរថយន្តរបស់គាត់។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០បន្តត្រូវបានដាក់បញ្ចូលគ្នាដោយសិប្បករបាននាំយកដែលបានកែប្រែសមាសធាតុឱ្យសមនឹងផលិតផលរបស់ពួកគេ។ ជាមួយនឹងការមកដល់នៃផ្នែកស្តង់ដារនៅឆ្នាំ ១៩០៨ បន្តដោយខ្សែបដិវត្តន៍របស់ Fond ដែលបានណែនាំនៅឆ្នាំ១៩១៣ ពេលវេលាដែលត្រូវការក្នុងការសាងសង់ម៉ូឌែល T បានធ្លាក់ចុះពីប៉ុន្មានថ្ងៃ មកត្រឹមប៉ុន្មានម៉ោងប៉ុណ្ណោះ (Klaess ២០២០)។ តាមទស្សនៈរបស់អ្នកគ្រប់គ្រង សិប្បករដែលមានជំនាញ គឺមិនចាំបាច់ក្នុងការផលិតរថយន្តទៀតទេ។ ការប្រើប្រាស់កម្លាំងពលកម្មដែលមានតម្លៃទាប និងការកើនឡើងនៃផលិតកម្មដែលទទួលបានដោយការផ្លាស់ប្តូរខ្សែសង្វាក់ផលិតកម្មបានអំពាវនាវឱ្យមានតម្រូវការណែនាំ និងគ្រប់គ្រងប្រតិបត្តិការដ៏ធំទាំងនេះ (Wilson ២០១៥)។ ដើម្បីទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗ វិធីសាស្ត្រផ្សេងគ្នាចំពោះរចនា សម្ព័ន្ធស្ថាប័ន និងការគ្រប់គ្រងត្រូវបានទាមទារ។ នៅឆ្នាំ ១៩៨១ លោកប្រធានាធិបតី Ronald Reagan, OMB និងនាយកផ្នែកស្ទាបស្ទង់លើការត្រួតពិនិត្យថ្លៃដើមវិស័យឯកជន ( The PresiDent's Private Sector Survey on Cost Control ) បាននិយាយថាសហព័ន្ធរដ្ឋាភិបាលអាចសន្សំប្រាក់បានច្រើនដោយការគ្រប់គ្រងសាច់ប្រាក់បានល្អត្រឹមត្រូវយ៉ាងប្រុងប្រយ័ត្នដូចជាការគ្រប់គ្រងសាច់ប្រាក់របស់អាជីវកម្មពួកគេ។ នាយកដ្ឋានបានគ្រប់គ្រងហិរញ្ញវត្ថុបានធ្វើអាទិភាពបញ្ឈប់នៃការចំណាយមិនចាំបាច់នៅក្នុងលំហូរសាច់ប្រាក់ទាំងអស់។ នៅក្នុងឆ្នាំ ១៩៨១-១៩៨២ ត្រូវបានផ្នែកមួយនៃកម្មវិធីកែលម្អការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ។ ទម្រង់ ៨៨ ត្រូវបានបង្កើតជាកម្មវិធីដ៏ទូលំទូលាយមួយដើម្បីធ្វើការកែលម្អពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាលតាមការបរិច្ឆេទកំណត់ក្នុងឆ្នាំ ១៩៨៨។ ទម្រង់ ៨៨ នេះបានដាក់វិធីដ៏ទូលំទូលាយមួយ ដើម្បីកែលម្អពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាល តាមកាលបរិច្ឆេទកំណត់នៃឆ្នាំ១៩៨៨។ ទម្រង់ ៨៨ ដាក់វិធីថ្មីទៅក្នុងការគ្រប់គ្រងសាច់ប្រាក់ សហព័ន្ធភ្នាក់ងារនីមួយៗត្រូវបានទាមទារ ដើម្បីត្រួតពិនិត្យ លំហូរសាច់ប្រាក់របស់ខ្លួនជ្រើសរើសល្អបំផុតសម្រាប់ការប្រមូលយ៉ាងលឿនទៅរកមាគ៌ា និងពេលវេលាទូទាត់ដល់អ្នកលក់ អ្នកទទួលប្រាក់ និងអ្នកទទួលការទូទាត់ផ្សេងៗទៀត។ មុនឆ្នាំ១៩៨២ រដ្ឋាភិបាលរបស់សហរដ្ឋអាមេរិកបង្កើត ៣០% នៃចំណាយដែលយឺតបំផុត និង ៤៥% លឿនបំផុត ហើយក៏ដាក់បញ្ចូលច្បាប់ ចំណាយនៅឆ្នាំ១៩៨២ និងធ្វើវិសោធកម្មក្នុងឆ្នាំ១៩៨៨។ OMB បានចេញបទបញ្ញត្តិ ដើម្បីអនុវត្តច្បាប់ដោយផ្តល់ការបញ្ចុះតម្លៃនៅពេលអតិថិជនទូទាត់ភ្លាមៗ ឬទាន់ពេលកំណត់។ ឆ្នាំ១៩៨៤ រដ្ឋាភិបាលបានចេញច្បាប់ និងបទបញ្ញត្តិលើការកាត់បន្ថយការធ្លាក់ចុះទឹកប្រាក់។ ការប្រមូល និងដាក់ភ្លាម បន្ទាប់ពីប្រមូលបានការទទួលការចំណាយក៏បានជ្រើសរើសតាមប្រព័ន្ធអេឡិចត្រូនិចដោយមានការផ្ទេរមូលបត្រ Lockboxes និងការដកទទួលមូលបត្រស្វ័យប្រវត្តិ។ បទបញ្ញត្តិការប្រមូល និងការដាក់ក្នុងរតនាគារក៏ត្រូវឱ្យ FMS ត្រួតពិនិត្យ ការគ្រប់គ្រងការប្រមូលប្រាក់ Cash Management Improvement Act ត្រូវបានអនុម័តក្នុងឆ្នាំ១៩៩០ ដោយផ្លាស់ប្តូរការផ្ទេរប្រាក់រវាង Federal Government និងរដ្ឋក្នុងគោលបំណង (១) ធានាបាននូវប្រសិទ្ធិភាព (២) ផ្តល់ប្រសិទ្ធភាព និង (៣) ធានានូវទ្រព្យ ។ ឆ្នាំ១៩៩៣ លោកប្រធានាធិបតី Bill Clinton បានបញ្ជាក់ពីបញ្ហាការផ្តល់ដំណោះស្រាយ និងគំនិតសម្រាប់សន្សំ។ នៅថ្ងៃទី ២៦ មេសា ១៩៩៦ សភាបានចេញច្បាប់ Debt

Collection Improvement Act of ១៩៩៦ ដោយចាប់ផ្តើមប្រើកម្មវិធី EFT។ កណ្តាលក្នុងរយៈពេលជាច្រើនសតវត្ស ធនាគារលក់រាយដែលមានស្រាប់ចាស់ជាងគេគឺ Banca Monte dei Paschi di Siena (បង្កើតក្នុង ឆ្នាំ ១៤៧២) ខណៈដែលធនាគារពាណិជ្ជដែលមានស្រាប់ចាស់ជាងគេគឺធនាគារ Berenberg (បង្កើតឡើងក្នុងឆ្នាំ១៥៩០)[3]។

## ២.២ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ធនាគារ

### ២.២.១ និយមន័យហិរញ្ញវត្ថុ

**ហិរញ្ញវត្ថុ (Finance)** គឺជាវិស័យដែលទាក់ទងនឹងការគ្រប់គ្រង និងការប្រើប្រាស់ធនធានសេដ្ឋកិច្ច ដើម្បីសម្រេចបានផែនការសេដ្ឋកិច្ច និងការវិនិយោគ។ មានទាក់ទងទៅនឹងការប្រមូលថវិកា ការវិនិយោគ ការចំណាយ និងការគ្រប់គ្រងហានិភ័យ។

**ហិរញ្ញវត្ថុ** គឺជាប្រព័ន្ធនៃការប្រើប្រាស់ ការគ្រប់គ្រង និងការបែងចែកធនធានសេដ្ឋកិច្ច ដោយផ្អែកលើការធ្វើសេចក្តីសម្រេចចិត្តតាមផែនការសេដ្ឋកិច្ច។ ហិរញ្ញវត្ថុមានទាក់ទងនឹងដំណើរការវិនិយោគ ការគ្រប់គ្រងហានិភ័យ ដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច[4]។

### ២.២.២ ប្រវត្តិហិរញ្ញវត្ថុ

រូបិយវត្ថុ ជាចំណែកមួយនៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង ដែលប្រព្រឹត្តទៅឥតឈប់ឈរនេះហើយ គេចាត់ទុកមុខងារចំបាច់របស់វា ជាប្រេងរំអិលនៃសកម្មភាពសេដ្ឋកិច្ច ។ ការសិក្សាសេដ្ឋកិច្ចនៃរូបិយវត្ថុ គឺជាការពិចារណាស៊ីជម្រៅ ពីមុខងាររបស់សេដ្ឋកិច្ចទីផ្សារបែបទំនើប និងមាគ៌ាដែលរដ្ឋាភិបាលអាចត្រួតពិនិត្យផលិតផលភាពគ្មានការធ្វើ (និកម្មញភាព) និងអតិផរណា ។ នៅពេលដែលរូបិយវត្ថុរៀបចំបានល្អផលិតផលអាចកើតឡើងសន្សឹមៗដោយគ្មានការរអាក់រអួល ទន្ទឹមនឹងថ្លៃមានស្ថេរភាព។ ប៉ុន្តែពេលខ្លះ មេការនិចរូបិយវត្ថុក៏មានការរអាក់រអួលដែលបណ្តាលឲ្យបរិមាណរូបិយវត្ថុកើនឡើងយ៉ាងឆាប់រហ័ស ឬ ក៏ត្រូវថយចុះច្រើនដែរ ហើយអតិផរណា ឬ ការធ្លាក់ថ្លៃប្រាកដជានឹងកើតឡើងតាមគន្លងនៃការប្រែប្រួលរបស់រូបិយវត្ថុនេះជាមិនខាន។ ការស្ទាបស្ទង់បញ្ហារបស់សេដ្ឋកិច្ចបច្ចុប្បន្ន ចាប់តាំងពីអតិផរណាកំរិតធ្ងន់នៅអាមេរិចខាងត្បូង រហូតដល់ភាពច្របូកច្របល់នៃសេដ្ឋកិច្ចសហភាពសូវៀតដល់ការបរាជ័យការសន្សំ និងការខ្ចីរបស់សហរដ្ឋអាមេរិច ដែលជានិច្ចកាលគេរកឃើញថាវិបត្តិនេះនៅក្នុងការគ្រប់គ្រងចាត់ចែងរូបិយវត្ថុ និងហិរញ្ញប្បទាន។ សារប្រយោជន៍ និងអត្រាការប្រាក់របស់រូបិយវត្ថុ ការវិវត្តន៍របស់រូបិយវត្ថុ៖ ប្រព័ន្ធហិរញ្ញវត្ថុទំនើបបច្ចុប្បន្ន មានសាច់ប្រាក់ផ្ទាល់ មូលប្បទានប័ត្រ ម៉ាស៊ីនទូទាត់ស្វ័យប្រវត្តិ និងឧបករណ៍ហិរញ្ញវត្ថុដ៏ស្មុគស្មាញមួយចំនួនទៀត គឺមិនមែនកើតឡើងត្រឹមតែមួយថ្ងៃមួយយប់ឯណាឡើយ។ ពពួកដូចបានរៀបរាប់ខាងលើបានវិវត្តន៍ ជាច្រើនសតវត្សមកហើយ។ ក៏ប៉ុន្តែនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ គឺជារូបិយវត្ថុដែលមានអត្ថន័យដូចតទៅ រូបិយវត្ថុ គឺជាអ្វីមួយដែលជាមធ្យោបាយដោះដូរ គឺជាមធ្យោបាយទូទាត់។ រូបិយវត្ថុទំនិញ គឺជាប្រភេទរូបិយវត្ថុដំបូងបំផុត ក៏ប៉ុន្តែការឆ្លងកាត់រយៈពេលប្រាំមួយខែរូបិយវត្ថុ និងទំនិញបានវិវត្តន៍ទៅជាក្រដាសប្រាក់ខ្ទង់គណនីមូលប្បទានបត្រ ។ ក្រដាសប្រាក់ និងខ្ទង់គណនីមូលប្បទានប័ត្រ មានសារប្រយោជន៍ដូចគ្នា គឺពួកវាមានមធ្យោបាយ

---

[3] FHSU Digital Press. Pressbooks. (2019, March, 21) *ប្រវត្តិនៃការគ្រប់គ្រង*. Retrieved from https://fhsu.pressbooks.pub

[4] Wikipedia. (2018, April 25). *និយមន័យហិរញ្ញវត្ថុ*. Retrieved from https://km.wikipedia.org/wiki

ទូទាត់ទំនិញ និងសេវាកម្ម។ ការដូរទំនិញដុល ដោយមិនប្រើរូបិយវត្ថុ(បារ-ទ័រ=Barter)។ ក្នុងផ្នែកដំបូងបង្អស់នៃអត្ថបទស្តីពីហិរញ្ញវត្ថុ ដោយចង់បង្ហាញពីសារជាតិរបស់ Barter លោក Stanley jevons បានប្រើឧទាហរណ៍ដូចតទៅៈ ប៉ុន្មានឆ្នាំកន្លងទៅ កញ្ញា Zelie ជាអ្នកចំរៀងនៅរោងល្ខោន Lirifque នៅ Paris បានទៅច្រៀងនៅក្នុងប្រជុំកោះមួយ។ ក្នុងការដោះដូរចំរៀងមួយចំនួន នាងបានទទួល១ភាគ៣ នៃបង្កាន់ដៃ។ ពេលបានរាប់ចំណែករបស់នាង នាងត្រូវបានគេរកឃើញថាមាន ជ្រូក៣ក្បាល មាន់បារាំង ២៣ក្បាល មាន់សម្លរ ៤៤ក្បាល ផ្លែដូងចំនួន ៥,០០០ផ្លែ ហើយនឹងចេក ក្រូចពោធិ៍សាត់ទៀត ។មានតំលៃប្រហែល ៤,០០០ ហ្វ្រង់ ដែលជាការតបស្នងការច្រៀងរបស់នាង។ នៅក្នុងសង្គមនោះទោះជាយ៉ាងណាតម្លៃនៃ រូបិយវត្ថុពុំទាន់មាន ឬ កម្រមាននរណាដឹងណាស់ថានាងពុំបានយករូបិយវត្ថុដែលនាងបានទទួលនោះ យកទៅប្រើប្រាស់ចាយវាយបានឡើយ នាងចាំបាច់ត្រូវតែរកផ្លែឈើមកចិញ្ចឹមសត្វជ្រូក និងសត្វផ្សេងៗទៀតរបស់នាង។ ឧ. ដូចដែលបានអធិប្បាយពីរូបិយវត្ថុ ដែលមានការចេះដោះដូរពីទំនិញជាមួយនឹងទំនិញមួយទៀត បារទៀមានលក្ខណៈផ្ទុយគ្នា និងសេដ្ឋកិច្ចរូបិយវត្ថុដែលយករូបិយវត្ថុជាមធ្យោបាយដោះដូរក្នុងការធ្វើជំនួញ។ បារទៀគ្មានលក្ខណៈងាយស្រួលក្នុងការដោះដូរជាក់ស្តែងឡើយ (ដូចដែលបានបង្ហាញក្នុងឧទាហរណ៍: ចំរៀងមួយបទ ដូរយកសត្វជ្រូក) គឺវាគ្រាន់តែបំពេញកង្វះខាតផ្ទាល់ខ្លួន។ ជាងនេះទៀត ប្រតិបត្តិការបារទៀស្ថិតក្រោមទម្រង់ចាញ់ប្រៀប ពីព្រោះការ បែងចែកយ៉ាងល្អិតល្អន់នៃពលកម្មអាច និងមិនគិតដល់ការប្រឌិតឡើងនៃរូបិយវត្ថុ។ ដូចជា ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រជាជនមិនអាចដោះដូរត្រង់ៗពីទំនិញមួយទៅទំនិញមួយបានឡើយ។ គេជំនួសការលក់ទំនិញទៅជារូបិយវត្ថុ ហើយបន្ទាប់មកគេប្រើរូបិយវត្ថុនេះ ដើម្បីទិញទំនិញមួយផ្សេងទៀតដែលគេគិតថាមានលក្ខណៈប្រសើរជាង ក្រឡេកមើលដំបូងវាហាក់ដូចជាមានការស្មុគ្រស្មាញជាងលក្ខណៈសាមញ្ញដោយជំនួសប្រតិបត្តិការមួយជាពីរ [5]។

### ២.២.៣ ទ្រឹស្តីហិរញ្ញវត្ថុ

ហិរញ្ញវត្ថុ សំដៅលើគោលការណ៍ គំរូ និងក្របខ័ណ្ឌដែលពន្យល់ពីរបៀបដែលទីផ្សារហិរញ្ញវត្ថុដំណើរការរបៀបបុគ្គល និងស្ថាប័នធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងរបៀបដែលហិរញ្ញវត្ថុត្រូវបានគេធ្វើការវាយតម្លៃ។ ហិរញ្ញវត្ថុ គឺជាវិស័យអន្តរកម្មសិក្សាដែលគូរចេញពីសេដ្ឋកិច្ច គណិតវិទ្យា ស្ថិតិ និងចិត្តវិទ្យា[6]។

## ២.៣ សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ

### ២.៣.១ និយមន័យធនាគារ

ធនាគារត្រូវបានឱ្យនិយមន័យជាច្រើនដូចជាៈ

ធនាគារ គឺជាអន្តរការីហិរញ្ញវត្ថុដែលផ្តល់នូវសេវាកម្មផ្នែកហិរញ្ញវត្ថុយ៉ាងទូលំទូលាយ ជាពិសេសការផ្តល់ឥណទាន ការទទួលប្រាក់បញ្ញើ ការបម្រើសេវាកម្មទូទាត់ និងអនុវត្តនូវមុខងារហិរញ្ញវត្ថុនៃក្រុមហ៊ុនសាជីវកម្មក្នុងសេដ្ឋកិច្ច។

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុមួយដែលផលិត និងលក់មូលបត្រជាសាធារណៈប្រកបដោយវិជ្ជាជីវៈ និងបានដើរតួយ៉ាងសំខាន់នៅក្នុងផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម[7]។

---

[5] Wikipedia. (2019, July14). *ប្រវត្តិហិរញ្ញវត្ថុ*. Retrieved from https://km.wikipedia.org/wiki

[6] Brealey, R. A., Myers, S. C., & Allen, F. (2020). *Principles of Corporate Finance* (13th ed.). McGraw-Hill Education.

[7] WordPress. Khem Sarith. (2016, October 04) *និយមន័យធនាគារ*. Retrieved from https://khemsarith.wordpress.com

### ២.៣.២ ប្រវត្តិនៃធនាគារ

ក្នុងដំណើរការនៃការកកើតរបស់ធនាគារ គឺគ្មានអ្នកណាដឹងពិតប្រាកដទេថាអាជីវកម្មនេះបានចាប់កំណើតតាំងពីពេលណាមកទេ ប៉ុន្តែតាមការស្រាវជ្រាវបានឱ្យដឹងថា ធនាគារមានដើមកំណើតមកពីប្រទេសអ៊ីតាលីថា Banca ដែលមានមូលដ្ឋានមកពីពាក្យអាឡឺម៉ង់ថា Bank ហើយប្រែជាភាសាអង់គ្លេសថា Bench មានន័យថាជាហាងមាស ឬជាតូបប្តូរប្រាក់នៅសម័យបុរាណ។ នាសម័យកាលនោះហាងមាសទទួលប្រាក់បញ្ញើជាមាស និងហិរញ្ញវត្ថុដែលមានតម្លៃដទៃទៀតក្នុងករណីខ្លះក៏ផ្តល់ជាប្រាក់ទៅលើការផ្ញើនេះ។ នៅពេលអតិថិជនផ្ញើមាស និងទទួលវិក្កយបត្រដែលចេញដោយជាងមាសក្នុងនោះបានបញ្ជាក់ពីចំនួន និងប្រភេទនៃមាសដែលបានផ្ញើ។ ក្រោយមកអ្នកផ្ញើមាសយល់ឃើញថា ការទូទាត់ដោយប្រើវិក្កយបត្រជាងមាសមានភាពងាយស្រួល និងមានសុវត្ថិភាពជាងការចាយមាសផ្ទាល់ ហើយចាប់តាំងពីពេលនោះមកវិក្កយបត្រជាងមាសក៏ដំណើរការដូចជាលុយដែរនាពេលបច្ចុប្បន្នមានឈ្មោះថាមូលប្បទានបត្រ។ ដោយឆ្លងកាត់រយៈពេលគន្លងមកជាងមាសបានពិនិត្យឃើញថាមាសដែលអតិថិជនបានយកមកផ្ញើអាចរក្សាទុកនូវតម្លៃមួយថេរ នៅក្នុងឃ្លាំងដោយសារក្នុងកុងត្រាជាមួយគ្នាអតិថិជនបានដកមាសពីឃ្លាំងរបស់ជាងមាស រីឯមួយចំនួនទៀតយកមកផ្ញើសារជាថ្មី។ ចាប់តាំងពីពេលនោះមក នៅក្នុងហាងមាសក៏បានផ្តល់ជាប្រាក់កម្ចីទៅឱ្យអតិថិជនមួយចំនួនផ្សេងទៀត តាមរយៈការបោះវិក្កយបត្របន្ថែម ដែលតម្រូវទៅតាមចំនួនមាសក្នុងឃ្លាំង វាជាការចាប់កំណើតធនាគារតាំងពីពេលនោះមក[8]។

### ២.៣.៣ ទ្រឹស្តីនៃធនាគារ

ទ្រឹស្តីនៃធនាគារ គឺជាការសិក្សាអំពីការបង្កើត និងការប្រើប្រាស់ធនាគារដើម្បីគ្រប់គ្រងធនធានហិរញ្ញវត្ថុ។ វាប្រើប្រាស់ដើម្បីបង្កើតសេវាកម្មហិរញ្ញវត្ថុដូចជា ការប្រាក់ ការបង់ប្រាក់ និងការប្រាក់សន្សំ។ ធនាគារ ជាអង្គភាពសំខាន់ក្នុងប្រព័ន្ធសេដ្ឋកិច្ច ដោយផ្តល់ជូនសេវាកម្មដែលជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ[9]។

[8] រៀបរៀងដោយនិស្សិតឈ្មោះសិស្សច្បងនៃវិទ្យាស្ថានវ៉ាន់ដា(២០២២) : ប្រធានបទ៖ *ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ អេស៊ីលីដាភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី១៩ នៃវិទ្យស្ថាន វ៉ាន់ដា. ទំព័រទី៥. ភ្នំពេញ។

[9] Mishkin, F. S. (2019). *The Economics of Money, Banking, and Financial Markets* (12th ed.). Pearson.

# ជំពូកទី៣
# ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារអេស៊ីលីដា សាខាម៉ៅសេទុង

## ៣.១ ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីដា

### ៣.១.១ ប្រវត្តិរបស់ធនាគារ អេស៊ីលីដា

ដោយមានការជួយគាំទ្រពីអង្គការពលកម្មអន្តរជាតិ (ILO) និងកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP) អេស៊ីលីដា ត្រូវបានបង្កើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៩៣ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយមានទិសដៅក្នុងការអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងខ្នាតតូចតាមរយៈការផ្តល់ឥណទានដោយស្ថាបនិកមួយក្រុមដូចខាងក្រោម។ តាំងពីពេលចាប់ផ្តើមដំបូង អេស៊ីលីដា បានទទួលការគាំទ្រពីភ្នាក់ងារអភិវឌ្ឍអន្តរជាតិសំខាន់ៗ ជាច្រើនដូចមាននៅក្នុងតារាងកិត្តិយសដែលយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ។ ការពង្រីកបណ្តាញប្រតិបត្តិការគ្របដណ្តប់គ្រប់ខេត្ត-រាជធានី ក្នុងព្រះរាជាណាចក្រកម្ពុជា និងមានសមត្ថភាពរបស់ធនាគារ ក្នុងការស្វែងរកប្រាក់ចំណេញដែលជានានូវនិរន្តរភាព គឺជាកត្តាធំពីរដែលធ្វើឱ្យក្រុមប្រឹក្សាភិបាល និងដៃគូអន្តរជាតិរបស់ខ្លួនសម្រេចថា ធនាគារ អេស៊ីលីដា គួរធ្វើការកម្លាយខ្លួនទៅជាធនាគារពាណិជ្ជ។ ធ្វើបែបនេះ មិនត្រឹមតែជួយពង្រឹងស្ថិរភាពរចនាសម្ព័ន្ធផ្នែកច្បាប់ សម្រាប់បំពេញកាតព្វកិច្ចរបស់ខ្លួនពីមុនមកនោះទេ វាថែមទាំងផ្តល់ឱ្យធនាគារនូវជម្រើសកាន់តែច្រើនក្នុងការរកទុនបន្ថែម ដូចជា ការបន្ថែមដើមទុន ការទទួលប្រាក់ បញ្ញើសាធារណៈ ឬការទទួលប្រាក់កម្ចីពាណិជ្ជកម្ម រវាងធនាគារដូចគ្នាសម្រាប់គាំទ្រដល់ការពង្រីក ការផ្តល់សេវា មីក្រូហិរញ្ញវត្ថុ ដែលជាអាជីវកម្មស្នូលរបស់ខ្លួន ។ ដោយមានការជួយជ្រោមជ្រែងពីស្ថាប័នផ្សេងៗ រួមទាំងភ្នាក់ងារអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក កម្មវិធីអភិវឌ្ឍលើវិស័យឯកជននៃតំបន់ទន្លេមេគង្គ (MPDF/IFC) និងកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP) ធ្វើឱ្យកម្មវិធីកម្លាយខ្លួនរយៈពេលបីឆ្នាំ ត្រូវបានលើកឡើងនៅឆ្នាំ១៩៩៨ ហើយសម្រេចជោគជ័យ ដោយទទួលបានអាជ្ញាប័ណ្ណជាធនាគារឯកទេស នៅក្នុងខែតុលា ឆ្នាំ២០០០។

នៅក្នុងដំណើរការកម្លាយខ្លួននេះ អង្គការក្រៅរដ្ឋាភិបាលអេស៊ីលីដាជាដើមបានបង្វែរទ្រព្យសកម្ម និងបំណុលក្នុងដៃអតិថិជនប្រាក់កម្ចីរយៈពេលវែង ដែលបានពីម្ចាស់ជំនួយទៅកាន់ធនាគារ អេស៊ីលីដា ដែលទើបបង្កើតថ្មីដោយប្តូរត្រឡប់ទៅវិញជាភាគហ៊ុន ៤៤,៩១% របស់ធនាគារស្មើនឹង ៤ លានដុល្លារ អាមេរិក សមាគមបុគ្គលិកអេស៊ីលីដា (ក្រុមហ៊ុន អេ អេស អេ អ៊ីន្ស) ដែលបានបង្កើតឡើងដោយមូលនិធិរបស់បុគ្គលិក បានទិញភាគហ៊ុនចំនួន ៦,០៩% ហើយចំណែកដែលនៅសល់ ៤៩% ទៀតត្រូវបានបែងចែកទៅឱ្យភាគហ៊ុនិកបរទេសចំនួនបួន គឺជាសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិសាខារបស់ធនាគារពិភពលោក DEG ប្រទេស អាល្លឺម៉ង់ FMO និងធនាគារទ្រីយ៉ូដូសប្រទេសហូឡង់។ នាពេលអនាគតធនាគារ អេស៊ីលីដា អាចនឹងមានវត្តមាននៅក្នុងទីផ្សារភាគហ៊ុនក្នុងពេលសមស្របណាមួយ។

បន្ទាប់ពីបង្កើនដើមទុនរបស់ខ្លួនមួយទ្វេរជាបីឡើងដល់ ១៣ លានដុល្លារធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ហើយត្រូវប្តូរឈ្មោះមកជា "ធនាគារ អេស៊ីលីដា ភីអិលស៊ី" ។




ធនាគា អេស៊ីលីដា សាខាម៉ៅសេទុង

### ៣.១.២ បេសកកម្ម ទស្សនវិស័យ របស់ធនាគារ អេស៊ីលីដា

ក. បេសកកម្ម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មប្រកបដោយនវានុវត្តន៍ និងសុវត្ថិភាព ដើម្បីជាមធ្យោបាយក្នុងការគ្រប់គ្រងចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថានប្រកបដោយកម្រិតខ្ពស់បំផុត ក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង និងបង្កើនអត្ថប្រយោជន៍ជូនដល់គ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូលប្រកបដោយនិរន្តរភាព។

ខ. ទស្សនវិស័យ

ជាធនាគារពាណិជ្ជនាំមុខដែលលោកអ្នកជឿទុកចិត្តបំផុតនៅប្រទេសកម្ពុជា ក្នុងការផ្តល់ និងបម្រើសេវាកម្មហិរញ្ញវត្ថុ ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។

### ៣.១.៣ ទីតាំង និងសាខារបស់ធនាគារ អេស៊ីលីដា

- ទីស្នាក់ការ

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យកណ្តាលរបស់ធនាគារ អេស៊ីលីដា គឺស្ថិតនៅរាជធានី ភ្នំពេញ។ ធនាគារ អេស៊ីលីដា មានបុគ្គលិកបម្រើការងារសរុបចំនួន ១២,១៨៧នាក់ ដែលបានបំពេញភារកិច្ចយ៉ាងសកម្មនៅក្នុងសាខាគ្រប់ខេត្ត-រាជធានីក្នុងព្រះរាជាណាចក្រកម្ពុជា។

➢ សាខារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា មានសាខាសរុបទាំងអស់ចំនួន ២៦២ នៅក្នុង ២៥ ខេត្ត-រាជធានីនៅក្នុងនោះរួមមានខេត្តដូចជា៖ រាជធានីភ្នំពេញ កណ្តាល កំពង់ចាម បាត់ដំបង ព្រៃវែង សៀមរាប កំពង់ធំ តាកែវ ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត កែប ព្រះសីហនុ កោះកុង ព្រះវិហារ ក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង បន្ទាយមានជ័យ ស្វាយរៀង ត្បូងឃ្មុំ ឧត្តរមានជ័យ និងប៉ៃលិន ។

### ៣.១.៤ ស្លាកសញ្ញា អត្ថន័យ និងគុណតម្លៃរបស់ធនាគារ អេស៊ីលីដា

**➢ ស្លាកសញ្ញា**

នៅក្នុងអំឡុងឆ្នាំ ១៩៩៣ មកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ភីអិលស៊ីបាន ប្តូរផ្លាស់នូវនិមិត្តសញ្ញាសម្គាល់របស់ខ្លួនជាច្រើនលើកគឺ៖

- **និមិត្តសញ្ញានាថ្ងៃ** • **និមិត្តសញ្ញានាថ្ងៃ**

(១៨ កុម្ភៈ ២០១៧ - ៣០ ធ្នូ ២០២០) (៣១ ធ្នូ ២០២០ - បច្ចុប្បន្ន)

**➢ អត្ថន័យ**

និមិត្តសញ្ញារបស់ ធនាគារ អេស៊ីលីដា មានពណ៌ ស មាស និងខៀវទឹកប៊ិក

-ពណ៌ ស៖ អភិសមាចារ (តម្លាភាព ភាពស្មោះត្រង់ និងសុចរិតភាព)

-មាស៖ គុណតម្លៃ និងគុណភាព

-ពណ៌ ខៀវទឹកប៊ិច៖ សាមគ្គីភាព ស្ថិរភាព និងសុវត្ថិភាព

រីឯពណ៌ទាំងបីបញ្ចូលគ្នា ប្រៀបទៅនឹងគ្រាប់ពូជ និងធនធានដែលបានរីកដុះដាល និងអភិវឌ្ឍក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព។

**➢ គុណតម្លៃ**

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារខ្មែរធ្វើប្រតិបត្តិការនៅប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ា ដែលប្តេជ្ញានឹងរក្សាគុណតម្លៃរបស់ខ្លួនជាមួយនឹងស្ថិរភាពហិរញ្ញវត្ថុ សុវត្ថិភាព សមត្ថភាព សុចរិតភាព គណនេយ្យភាព តម្លាភាព ភាពស្មោះត្រង់ បរិសុទ្ធ និងការយល់ចិត្ត។ តម្លៃទាំងនេះត្រូវបានកំណត់យ៉ាងច្បាស់ក្នុងអត្ថន័យនៃអក្សរជាភាសាខ្មែរ-អង់គ្លេស ‹‹អ-A,ស-C,ល-L,ដ-D (អេស៊ីលីដា ACLEDA)››

- អ(អភិសមាចារ)៖ ធនាគារផ្តោតលើការប្រព្រឹត្តរៀបរយគួរជាទីគាប់ចិត្ត គួរឱ្យជ្រះថ្លាដល់គ្រប់ភាគី រួមមានបុគ្គលិក អតិថិជន ដៃគូរអាជីវកម្ម និងសាធារណជនទូទៅ។
- ស(សុចរិតស្មោះត្រង់)៖ ធនាគារផ្តោតលើការបម្រើសេវាកម្មជូនអតិថិជន សាធារណជនប្រកបដោយសេចក្តីសុចរិត និងក្រមសីលធម៌វិជ្ជាជីវៈ។
- ល(លឿនទាន់ចិត្ត លទ្ធផលល្អ)៖ ធនាគារផ្តោតលើការបម្រើរហ័សទាន់ចិត្ត ផ្គាប់ចិត្ត ផ្តល់នូវទំនុកចិត្តខ្ពស់ជូនអតិថិជន សាធារណជនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលល្អ។
- ដ(ដុះដាលចម្រើនថ្កាន)៖ ធនាគារផ្តោតលើការអភិវឌ្ឍន៍គំនិតច្នៃប្រឌិតទាន់សម័យនៃគ្រប់ផលិតផល សេវាកម្ម ប្រកបដោយឧត្តមភាព និងវិបុលភាព។

### ៣.១.៥ សមាសភាពរបស់ក្រុមប្រឹក្សាភិបាល និងអភិបាល



**លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការសវនកម្ម**

ជនជាតិខ្មែរ កើតក្នុងខែមេសា ឆ្នាំ១៩៥៤ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែ សីហា ឆ្នាំ២០១៤។ លោកបានចូលបម្រើការជាមួយធនាគារ អេស៊ីលីដា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៣ រហូតដល់ចូលនិវត្តន៍នៅខែមេសា ឆ្នាំ២០១៤។ តួនាទីចុងក្រោយមុនចូលនិវត្តន៍របស់លោក នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអនុប្រធាន នាយកប្រតិបត្តិ និងជា គណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ។ លោកធ្លាប់ធ្វើជាគណនេយ្យករ និងជាអនុប្រធានគណនេយ្យករនៃមន្ទីរពាណិជ្ជកម្មខេត្តកំពត ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩២។

បច្ចុប្បន្នលោកឆាយ សឿន ជាប្រធានក្រុមប្រឹក្សាភិបាលនៃ ធនាគារ អេស៊ីលីដា ភីអិលស៊ី សមាជិកក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងជាសមាជិកក្រុមប្រឹក្សាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតប្រតិបត្តិគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក។ លោកក៏បានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន។



### បណ្ឌិត អ៊ិន ចាន់នី អភិបាល

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ លោកបណ្ឌិតជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា នៅខែសីហា ឆ្នាំ២០១៤។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍ សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលបានទទួលខុសត្រូវរៀបចំផែនការ យុទ្ធសាស្ត្ររួម និងដំណើរការអាជីវកម្មប្រចាំថ្ងៃ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្មរបស់ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះ ក្រុមប្រឹក្សាភិបាល។ ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ប្រទេសឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ឡាវ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងស្ថាប័ន មីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។ លោកបណ្ឌិតក៏ជាប្រធានក្រុមបរធនបាល អេស៊ីលីដា ហ្វាយណាន់ ហ្សល់ ត្រាស់។ ក្រៅពីលើសពីនេះ បណ្ឌិត អ៊ិន ចាន់នី ក៏ជាប្រធានសមាគមធនាគារនៅកម្ពុជាពីរអាណត្តិជាប់គ្នាពីឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២២។ បច្ចុប្បន្នលោកបណ្ឌិត ជាសមាជិកក្រុមប្រឹក្សានៃសមាគមធនាគារនៅកម្ពុជា និងជាសហប្រធានក្រុមការងារសេវាកម្មធនាគារ និងហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ១៩៩៨ លោកបណ្ឌិតបានបញ្ចប់វគ្គគ្រប់គ្រងស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍសហគ្រាសឯកជនពីសាកលវិទ្យាល័យHarvard សហរដ្ឋអាមេរិក។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មនិងបានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន (GAICD)។



### លោក Pieter Kooi អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រង ហានិភ័យ និងព័ត៌មានវិទ្យា (ប្រធាន), គណៈកម្មាធិការតែងតាំង និងលាភការ (ប្រធាន) គណៈកម្មាធិការសវនកម្ម

ជនជាតិហូឡង់ កើតក្នុងឆ្នាំ១៩៥៨ លោក Koo បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែតុលា ឆ្នាំ២០០០។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សា មីក្រូហិរញ្ញវត្ថុឱ្យ អេស៊ីលីដា រយៈពេលជាង៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍទៅជាធនាគារពាណិជ្ជ ចាប់ពីឆ្នាំ១៩៩៩ បានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុ រយៈពេលខ្លីនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង១៥ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ឆ្នាំ ២០០៥ មានតួនាទីជា នាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ទីក្រុងញូវយ៉ក។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់

ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ អេស៊ីលីដា ត្រេននីង សេនធ័រ (បច្ចុប្បន្នជាវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា)និង អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី បច្ចុប្បន្នលោកមានតួនាទីជាក្រុមប្រឹក្សាភិបាលជាច្រើននៅធនាគារ អេស៊ីលីដា គ្រុប។ លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហូឡង់។ លោកក៏បានបញ្ចប់ការសិក្សាពីវិទ្យាស្ថាន អូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន (GAICD)។



**បណ្ឌិត ហេង ឌីណា អភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា**

ជាជនជាតិខ្មែរ បណ្ឌិត ហេង ឌីណា បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលនៅខែធ្នូ ឆ្នាំ២០២៣ ដោយនាំមកនូវបទពិសោធន៍ជាង ១០ ឆ្នាំជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច នៅស្ថាប័នអន្តរជាតិ លោកបណ្ឌិត មានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការវិភាគហានិភ័យអំពីការឃ្លាំមើលម៉ាក្រូសេដ្ឋកិច្ច និងការវាយតម្លៃផ្នែកហិរញ្ញវត្ថុ។ លោកបណ្ឌិត ហេង ឌីណា ក៏ធ្លាប់បានដឹកនាំកម្មវិធីជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលជាច្រើនដល់មន្ត្រីធនាគារ កណ្តាល និងក្រសួងហិរញ្ញវត្ថុ នៅបណ្តាប្រទេសនៅអាស៊ី អាហ្វ្រិក និងអឺរ៉ុប។ បច្ចុប្បន្ន លោកបណ្ឌិត ហេង ឌីណា គឺជាអ្នកវិភាគសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម សេដ្ឋកិច្ចកម្ពុជា។ បណ្ឌិត ហេង ឌីណា បានបញ្ចប់កម្មវិធីគ្រប់គ្រងទ្រព្យសកម្ម និងផលបត្រ (Asset and Portfolio management Program) នៅសាលា Wharton និងទទួលបានសញ្ញាប័ត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យជាតិអូស្ត្រាលីក្នុងឆ្នាំ២០១២ លោកបណ្ឌិតក៏បានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Hitotsubashi ទីក្រុងតូក្យូ ប្រទេសជប៉ុន និងបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Nagoya បណ្ឌិត ហេង ឌីណា ក៏បានទទួលជ័យលាភីគណិតវិទ្យាទូទាំងប្រទេស (ចំណាត់ថ្នាក់លេខ៤) ក្នុងឆ្នាំ២០០០។



**លោកស្រី ភូរិ រតនា អភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការសវនកម្ម (ប្រធាន)**

ជនជាតិខ្មែរ និងមានសញ្ជាតិបារាំងកើតនៅឆ្នាំ១៩៧២ លោកស្រី ភូមិ រតនា បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែវិច្ឆិកា ឆ្នាំ២០២១ ហើយលោកស្រីក៏ជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានណិជ្ជសាស្ត្ររបស់អេស៊ីលីដា ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២២។ លោកស្រីជា CFA Charterholder។ លើសពីនេះ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់ក្រោយបរិញ្ញាបត្រ (DEA) និងជាបេក្ខជនបណ្ឌិត ជំនាញឧស្សាហកម្មសេដ្ឋកិច្ច បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ ជំនាញពាណិជ្ជកម្មបរទេស និង

បរិញ្ញាបត្រជាន់ខ្ពស់ សេដ្ឋកិច្ច និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យប៉ារីស១ Panthéon Sorbonne លោកស្រីក៏បានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន (GAICD)។ លោកស្រី រតនា មានបទពិសោធន៍២៥ឆ្នាំ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ ការអភិវឌ្ឍន៍ វិស័យឯកជន និងហិរញ្ញវត្ថុលោកស្រីមានប្រវត្តិផ្តើមជាទីប្រឹក្សា/អ្នកសេដ្ឋកិច្ច រួមទាំងមានបទពិសោធន៍ផ្ទាល់នៅក្នុងតួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់។ បច្ចុប្បន្ន លោកស្រី គឺជាទីប្រឹក្សាជាន់ខ្ពស់ សម្រាប់ការវិនិយោគ និង វិស័យឯកជនឱ្យអង្គការអន្តរជាតិផ្សេងៗ និងជាក្រុមប្រឹក្សាផ្តល់យោបល់ ដល់សហគ្រាសខ្មែរ អ៊ីមផែកហាប់ និង ស្តូលរើល។ លោកស្រី គឺជាអភិបាលឯករាជ្យនៅធនាគារពាណិជ្ជមួយ នៅកម្ពុជាចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០២១។ លោកស្រីបាន លាលែងតំណែងជា អភិបាលឯករាជ្យ នៅ I-Finance Leasing (ដោយក្រុមហ៊ុន បានលក់ទៅ គូកមី នាចុងឆ្នាំ២០២២) ហើយលោកស្រីបានក្លាយជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា។ បន្ថែមលើនេះលោកស្រី គឺជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៅ Cambodia Community of "Investment Professionals (សមាគមន៍ CFA នៅកម្ពុជា) ដើម្បីបណ្តុះបណ្តាលជំនាញ ផ្នែកហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់កម្ពុជាឱ្យក្លាយទៅជាគោលដៅវិនិយោគ។ តួនាទី កន្លងមកនៅកម្ពុជារបស់លោកស្រីមានជាអាទិ៍ អភិបាលប្រតិបត្តិ EuroCham Cambodia ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ទីប្រឹក្សាធុរកិច្ចនៅ DFDL ដៃគូនៅ private-equity firm Cambodia Emerald នៅឆ្នាំ២០០៨ និងអភិបាលនៅ CCFC (French Cambodian Chamber of Commerce)។ លោកស្រី ធ្លាប់បម្រើការងារនៅប្រទេសស្វីស ក្នុងតួនាទីជាអ្នកគ្រប់គ្រងមូលបត្រនៅធនាគារឯកជន និងជាអ្នកសេដ្ឋកិច្ចនៅ UNCTAD។



**លោក Stéphane MANGIAVACCA អភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការតែងតាំង និងលាភការ**

ជនជាតិបារាំង កើតក្នុងឆ្នាំ១៩៧៥ លោក Mangiavacca បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែមីនា ឆ្នាំ២០២០។ លោកបានចាប់ផ្តើមការងារក្នុងក្រសួងហិរញ្ញវត្ថុបារាំងនៅក្នុងប្រទេសចិន។ បន្ទាប់មក លោកបានចូលរួមជាមួយសវនកម្មផ្ទៃក្នុងនៃក្រុម BPCE ដែលលោកបានក្លាយជានាយកជាន់ខ្ពស់នៃ Quantitative Audit បច្ចុប្បន្នលោកបម្រើការឱ្យក្រុម BRED Banque Populaire មានតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិ និងជាប្រធានក្រុមអន្តរជាតិក្រោយមកក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារជាច្រើននៅក្នុងប្រទេសបារាំង និងអន្តរជាតិដែលគ្រប់គ្រងដោយក្រុម BRED។ លោកក៏ជាអតីតប្រធានផ្នែកហានិភ័យ និងអនុលោមបញ្ញត្តិរហូតដល់ខែមករា ឆ្នាំ២០២០។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ECOLE NATIONALE SUPERIEURE DES MINES DE SAINT ETIENNE វិស្វកម្ម និងបានសិក្សានៅ University of New Brunswick ក្នុងប្រទេសកាណាដា។



**លោក Kyosuke Hattori អភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា**

ជនជាតិជប៉ុនកើតក្នុង ឆ្នាំ១៩៧៥ លោក Kyosuke Hattori បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែវិច្ឆិកា ឆ្នាំ២០២១។ លោកបានចាប់ផ្តើមការងារជាមួយធនាគារ Sumitomo បច្ចុប្បន្នជា Sumitomo Mitsui Banking Corporation SMBC ក្រោយបញ្ចប់ការសិក្សាពី សាកលវិទ្យាល័យ Sophia។ នៅក្នុងខែមេសា ឆ្នាំ២០០១ លោក Kyosuke Hattori ត្រូវបានតែងតាំងជា Assistant Vice President ការិយាល័យធុរកិច្ចសាជីវកម្ម Shin-Yokohama នៅ SMBC។ នៅខែតុលា ឆ្នាំ២០០២ លោក Hattori ត្រូវបានតែងតាំងជា Assistant Vice-President ការិយាល័យសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម នៅ រាជធានីតូក្យូ។ នៅខែធ្នូ ឆ្នាំ២០០៣ លោកត្រូវបានផ្ទេរទៅបម្រើការងារនៅសាខាសិង្ហបុរី។ នៅខែកក្កដា ឆ្នាំ២០០៥ លោកត្រូវបានដំឡើងតំណែងជា Vice President នៃសាខាសិង្ហបុរី។ នៅខែកក្កដា ឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជា Vice-President នៃការិយាល័យទំនាក់ទំនងសាធារណៈនៅរាជធានីតូក្យូ។ នៅក្នុងខែតុលា ឆ្នាំ២០១២ លោកត្រូវបានដំឡើងតំណែងជា Senior Vice-President នៃការិយាល័យផែនការ សាជីវកម្មនៅរាជធានីតូក្យូ។ លោកត្រូវបានផ្លាស់ប្តូរកន្លែងបម្រើការងារនៅនាយកដ្ឋានធុរកិច្ចទីផ្សារកំពុងរីកលូតលាស់ និងការិយាល័យផែនការផ្នែកធនាគារអន្តរជាតិនៅខែមេសា ឆ្នាំ២០១៤ និងឆ្នាំ២០១៦ ជាបន្ត បន្ទាប់។ នៅខែមេសា ឆ្នាំ២០១៧ លោកត្រូវបានដំឡើងតំណែងជា Senior Vice President and Group Head នៃការិយាល័យផែនការផ្នែកធនាគារអន្តរជាតិ។ នៅខែមេសា ឆ្នាំ២០២០ លោកត្រូវបានផ្លាស់ប្តូរកន្លែងទៅបម្រើការងារនៅការិយាល័យអភិវឌ្ឍធុរកិច្ច នៅរាជធានីតូក្យូ បន្ទាប់មក លោកត្រូវបានផ្លាស់ប្តូរការងារទៅប្រទេសសិង្ហបុរី នៅខែមិថុនា ឆ្នាំ២០២១ ក្នុងតួនាទីជាសហប្រធានគ្រប់គ្រងទូទៅការិយាល័យផែនការ នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក បច្ចុប្បន្នលោក Hattori មានតួនាទីជាសហប្រធានគ្រប់គ្រងទូទៅនៅការិយាល័យធុរកិច្ចអាស៊ីនាយដ្ឋាន អាស៊ីប៉ាស៊ីហ្វិក។ លោក Hattori បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រឯកទេសច្បាប់ នៅខែមីនា ឆ្នាំ១៩៩៨។



**បណ្ឌិត Albertus Bruggink អភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការតែងតាំង និងលាភការ, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា**

ជនជាតិហូឡង់ កើតក្នុងឆ្នាំ១៩៦៣ លោកបណ្ឌិត Albertus Bruggink បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែឧសភា ឆ្នាំ២០២១។ ក្រៅពីធនាគារ អេស៊ីលីដា បច្ចុប្បន្នលោកបណ្ឌិតធ្វើជាទីប្រឹក្សាឯករាជ្យនៅប្រទេសហូឡង់ និងធ្វើជាអ្នកប្រឹក្សាសាជីវកម្មរបស់ក្រុមហ៊ុន ORIX - Corporation នៅតូក្យូ និងជាប្រធានគណៈកម្មាធិការសវនកម្មនៃ ORIX Europe លើសពីនេះទៀត លោក

បានចូលរួមជាមួយក្រុមប្រឹក្សាភិបាលមូលនិធិ Westerbork Fund(ប្រទេសហូឡង់)ក្នុងខែមករាឆ្នាំ២០២២។ លោកក៏បានបម្រើការងារនៅធនាគារ Rabobank អស់រយៈពេល៣០ឆ្នាំ ហើយលោកបានកាន់មុខតំណែងជាច្រើនដូចជា ហិរញ្ញវត្ថុ គ្រប់គ្រងហានិភ័យ និងរតនាភិបាល ទីផ្សារមូលធន ទាំងក្នុងស្រុក និងអន្តរជាតិ ដែលក្នុងនោះលោកកាន់តួនាទីជាអភិបាលប្រតិបត្តិ រយៈពេល១២ឆ្នាំ។ ក្នុងកំឡុងពេលបម្រើការងារ លោកបណ្ឌិតជាសមាជិកក្រុមប្រឹក្សាភិបាលជាច្រើន នៅក្នុងប្រទេសហូឡង់ និងកាន់តំណែង ជាប្រធានគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាលជាច្រើនអាណត្តិផងដែរ។ លោក Albertus Bruggik ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Twente នៅឆ្នាំ១៩៨៦ និងសញ្ញាបត្របណ្ឌិត ជំនាញវិស្វកម្មហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Twente នៅឆ្នាំ១៩៨៩។ បច្ចុប្បន្ន លោកបណ្ឌិត គឺជាសាស្រ្តាចារ្យជំនាញវិស្វកម្មហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ នៅសាកលវិទ្យាល័យ Twente។ បន្ថែមលើនេះ លោកបណ្ឌិតក៏មានតួនាទីជាសមាជិកនៃក្រុមប្រឹក្សាភិបាលផ្តល់យោបល់របស់ Medisch Spectrum Twente (ហូឡង់) Ormat Technologies(សហរដ្ឋអាមេរិក),TFG and XAC Bank(ម៉ុងហ្គោលី) និង Gravis Capital Management (ចក្រភពអង់គ្លេស)។



**លោក កាយ ឡូត អភិបាល**

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា**

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៧០ លោក កាយ ឡូត បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែឧសភា ឆ្នាំ២០២១។ លោក កាយ ឡូត ជាសហគ្រិនម្នាក់ដែលមានបទពិសោធន៍ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុធនាគារ ផ្សព្វផ្សាយ និងទូរគមនាគមន៍។ កាលពីមុន លោកធ្លាប់បានបម្រើការជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្មរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំមួយនៅកម្ពុជា។ បច្ចុប្បន្ន លោកគឺជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសិប្បករអង្គរ ដែលមានមូលដ្ឋាននៅខេត្តសៀមរាប និងជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សព្វផ្សាយឌីជីថល និងក្រុមហ៊ុនសំណង់។ លោកក៏ជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុន BSP Finance Cambodia និងDigital Divide Data ដែលជាក្រុមហ៊ុនដែលមានលក្ខណៈសង្គមមានមូលដ្ឋាននៅទីក្រុងញូវយ៉ក។ លោកបានទទួលវិញ្ញាបនបត្រ IFRS The Association of Chartered Certified Accountants និងសញ្ញាបត្រថ្នាក់អនុបណ្ឌិតពីសាលា Essec_Business School។ លោកក៏បានបញ្ចប់ការសិក្សាពី វិទ្យាស្ថាន អូស្រ្តាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

## ៣.២ ផែនការ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពរបស់ធនាគារអេស៊ីលីដា

### ៣.២.១ ការរៀបចំផែនការគ្រប់គ្រងហិរញ្ញវត្ថុ

ការរៀបចំផែនការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព អ្នករៀបចំត្រូវកំណត់គោលដៅហិរញ្ញវត្ថុ ការរៀបចំគម្រោងផែនការថវិកា ការប្រើឧបករណ៍ហិរញ្ញវត្ថុ វាយតម្លៃប្រាក់ចំណូល ចំណាយ ការព្យាករណ៍ពីលំហូរសាច់ប្រាក់ ការត្រួតពិនិត្យ និងវាយតម្លៃការរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាសជាមុន ដើម្បីរៀបចំជាដំណើរការទាំងមូលក្នុងការវាយតម្លៃ និងអភិវឌ្ឍយុទ្ធសាស្រ្តហិរញ្ញវត្ថុសម្រាប់អង្គភាព (ធុរកិច្ច មូល

និធិ ស្ថាប័ន និងរៀបចំថវិកា) ដើម្បីសម្រេចបានផែនការហិរញ្ញវត្ថុរបស់អង្គភាពឱ្យមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀតក៏បានរួមបញ្ចូលការកំណត់ធនធាន ការបែងចែកថវិកា ការវិភាគហានិភ័យ ការត្រួតពិនិត្យស្ថានភាពឥណទាន និងគោលដៅរយៈពេលខ្លី-វែង។ ដូច្នេះហើយ ដើម្បីសម្រេចបាននូវផែនការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

**ក. ការកំណត់ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា**

ការកំណត់ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា មានផែនការហិរញ្ញវត្ថុចម្បង ដើម្បីធានានូវស្ថិរភាពហិរញ្ញវត្ថុរបស់ខ្លួន។ ផែនការគ្រប់គ្រងហិរញ្ញវត្ថុទាំងនេះរួមមាន៖

.ការកំណត់ស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ដើម្បីទទួលបានប្រាក់ចំណេញប្រចាំឆ្នាំ ការគ្រប់គ្រងហានិភ័យឥណទាន ការរក្សាការវិនិយោគ ការបង្កើនចំណូលពីសេវាកម្មហិរញ្ញវត្ថុបង្កើនចំណេញសុទ្ធ និងតុល្យភាពហិរញ្ញវត្ថុយ៉ាងមានស្ថិរភាព។

.កំណត់ការគ្រប់គ្រងសេវាហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ទៅកាន់សហគមន៍ ផ្តល់ឱ្យអតិថិជននូវសេវាហិរញ្ញវត្ថុដែលមានគុណភាព ភាពទូលំទូលាយដោយការពង្រីកនូវសេវាកម្ម Mobile Banking, Digital Banking និងទៅកាន់សាខាថ្មីៗក្នុងការជំរុញសេវាឥណទានតូចមធ្យម (MSME) ដើម្បីគាំទ្រកសិករព្រមទាំងអាជីវកម្មខ្នាតតូចៗដែលជាអតិថិជនរបស់ធនាគារ អេស៊ីលីដា។

.កំណត់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ កាត់បន្ថយហានិភ័យ បង្កើតប្រព័ន្ធតាមដានសាច់ប្រាក់ បង្កើតច្បាប់គោលការណ៍គ្រប់គ្រងទ្រព្យសកម្មឱ្យមានប្រសិទ្ធភាព ក្នុងការវិនិយោគបច្ចេកវិទ្យាថ្មីៗសម្រាប់សុវត្ថិភាព និងភាពឆាប់រហ័សនៅក្នុងធនាគារ អេស៊ីលីដា។

.ធ្វើការអភិវឌ្ឍន៍ធនធានមនុស្សរបស់ធនាគារ អេស៊ីលីដា តាមរយៈការបណ្តុះបណ្តាលបុគ្គលិកឱ្យមានជំនាញវិជ្ជាជីវៈរក្សាភាពច្នៃប្រឌិត និងការងារដែលមានគុណភាពខ្ពស់។

.កំណត់ផែនការយុទ្ធសាស្ត្រដើម្បីចូលរួមការងារសង្គម CSR ជួយសហគមន៍បរិស្ថានផ្តល់ការគាំទ្រដល់ការអប់រំ និងសុខភាពសាធារណជន។

**ខ. ការរៀបចំគម្រោងផែនការថវិការបស់ធនាគារ អេស៊ីលីដា**

ការរៀបចំគម្រោងផែនការថវិការបស់ធនាគារ អេស៊ីលីដា (ACLEDA Bank) ជាផែនការដ៏សំខាន់មួយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធិភាព ធនាគារត្រូវតែរៀបចំ កំណត់គោលដៅហិរញ្ញវត្ថុ វិភាគ ស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន ការបែងចែកថវិកា ការព្យាករណ៍លើលំហូរសាច់ប្រាក់ ដាក់បញ្ចូលគោលនយោបាយហិរញ្ញវត្ថុ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធាន ប្រាក់ចំណូលពីសេវា និងប្រាក់ចំណូលផ្សេងៗ។

- ការរៀបចំគម្រោងផែនការការបែងចែកថវិកា (Budget Allocation) បន្ទាប់ពីមានព័ត៌មានពីការវិភាគផែនការហិរញ្ញវត្ថុធនាគារ អេស៊ីលីដា បានបែងចែកថវិកាទៅតាមផ្នែក និងគម្រោងនានា (IT, Marketing, Operations, HR)។ ការបែងចែកថវិកាជាបីប្រភេទដូចជា ថវិកាធម្មតា (ដំណើរការប្រចាំថ្ងៃ) ថវិកាវិនិយោគ (ដូចជា ការទិញ software ឬ ទ្រព្យសកម្មថេរ) ថវិកាបម្រុង (Contingency) សម្រាប់ការចំណាយអាសន្ន។

- រៀបចំផែនការព្យាករណ៍លើលំហូរសាច់ប្រាក់ (Cash Flow Forecasting) ជាការប៉ាន់ប្រមាណចំណូល និងចំណាយសម្រាប់ពេលខាងមុខ ហើយបង្កើតតារាង Cash In – Cash Out ដើម្បីវាយតម្លៃថាតើធនាគារនឹងខ្វះប្រាក់សាច់នៅពេលណា ដើម្បីចាត់វិធានការកែសម្រួលប្រសិនបើមានបញ្ហាខ្វះសាច់ប្រាក់ (short-term loans, overdraft line)។
- ការរៀបចំផែនការហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ជាដំណាក់កាលដំបូងសម្រាប់ការរៀបចំផែនការថវិការបស់ធនាគារ។ ជាមួយគ្នានេះដែរ ធនាគារ បានកំណត់ផែនការហិរញ្ញវត្ថុរបស់ខ្លួនយ៉ាងច្បាស់លាស់ដូចជា៖ ចំណូល ការកាត់បន្ថយបំណុល ការវិនិយោគលើសេវាឌីជីថល ដើម្បីងាយស្រួលគ្រប់គ្រងហិរញ្ញវត្ថុ។
- ការវិភាគផែនការហិរញ្ញវត្ថុបច្ចុប្បន្ន ជាដំណាក់កាលមួយដែលជួយឱ្យធនាគារ អាចត្រួតពិនិត្យពីចំណូល ចំណាយឆ្នាំកន្លងមកនៅក្នុងការវិភាគផែនការហិរញ្ញវត្ថុនេះដែលធនាគារ អេស៊ីលីដា បានប្រើប្រាស់វិធីសាស្ត្រ (Actual) ប្រៀបធៀបនឹងថវិកាដែលបានរំពឹង (Budgeted) ដើម្បីវាយតម្លៃសមត្ថភាពហិរញ្ញវត្ថុបច្ចុប្បន្ន និងសមតុល្យបំណុល។
- ការរៀបចំគម្រោងផែនការគោលនយោបាយហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ត្រូវបានបង្កើតគោលនយោបាយចំណាយត្រឹមត្រូវ (Spending policy) និងកំណត់លើបំណុលឱ្យត្រឹមត្រូវជាមួយនឹងសមត្ថភាពបង់ប្រាក់ត្រឡប់មកវិញ ក្នុងការដាក់ចេញនៅគោលនយោបាយអំពីការបង្កើតទុនបម្រុង (Reserves) ដើម្បីគាំទ្រដល់ការចំណាយចាំបាច់ណាមួយ។
- ការរៀបចំគម្រោងផែនការប្រព័ន្ធគ្រប់គ្រងធនធានរបស់ធនាគារ អេស៊ីលីដា ដោយបានប្រើប្រាស់ software និងប្រព័ន្ធឌីជីថលដូចជា៖

  -Core Banking System ចាត់ចែងប្រតិបត្តិការហិរញ្ញវត្ថុ

  -ERP system គ្រប់គ្រងផែនការថវិកា និងសមត្ថភាពលើគ្រប់ផ្នែក

  -Power BI / Excel dashboards ដើម្បីរៀបចំរបាយការណ៍ស្ថិតិ និងវិភាគប្រៀបធៀបថវិកា។
- ការរៀបចំគម្រោងផែនការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល (Monitoring and Evaluation) សម្រាប់តាមដានការចំណាយជាប្រចាំតាមតារាង (Monthly/Quarterly monitoring) និងបង្កើតរបាយការណ៍ Actual vs Budget។ បើមានការកែតម្រូវ ឬចំណាយលើសពីផែនការត្រូវដាក់បញ្ចូលនូវវិធានការសម្របសម្រួល ឬកាត់បន្ថយចំណាយក្នុងផ្នែកមិនចាំបាច់។
- ការរៀបចំគម្រោងផែនការប្រាក់ចំណូលពីសេវារបស់ធនាគារ អេស៊ីលីដា រួមមានថ្លៃសេវាជូនអតិថិជនដូចជា សេវាធនាគារ អេធីអឹម កាត និងសេវាប្រតិបត្តិការរបស់ធនាគារ។
- ការរៀបចំគម្រោងផែនការប្រាក់ចំណូលផ្សេងៗរបស់ធនាគារ អេស៊ីលីដា រួមមានការប្តូរប្រាក់ និងសេវាផ្សេងៗទៀត។

**. ចំណាយ (Expenses)**

ធនាគារចំណាយលើផ្នែកផ្សេងៗ ដូចជា៖

- បៀវត្ស/ប្រាក់ខែបុគ្គលិក៖ ចំណាយធំៗសម្រាប់បុគ្គលិកគ្រប់សាខា។
- ចំណាយលើអគារ និងការជួល៖ សម្រាប់ការប្រើប្រាស់អាគារ សាខា និងកន្លែងប្រតិបត្តិការ។
- ចំណាយបច្ចេកវិទ្យា៖ ការថែទាំប្រព័ន្ធ IT កម្មវិធី និង Server។
- បំណុលខាតបង់ (Loan Loss Provision)៖ ប្រាក់បម្រុងសម្រាប់ឥណទានដែលអាចមិនប្រមូលវិញបាន។
- ចំណាយផ្សេងៗ៖ រួមមានថ្លៃសេវាផ្សេងៗ ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងការគ្រប់គ្រងទូទៅ។

**. ចំណេញសុទ្ធ (Net Profit)**

ចំណេញសុទ្ធ (Net Profit) របស់ធនាគារ អេស៊ីលីដា គឺជាចំណូលសុទ្ធដែលបាននៅសល់ បន្ទាប់ពីដកចេញចំណាយទាំងអស់ពីចំណូលសរុប ដើម្បីប្រសិទ្ធភាពក្នុងប្រតិបត្តិការរបស់ធនាគារ និងសមត្ថភាពក្នុងការបង្កើតចំណូល។ចំណេញសុទ្ធក៏ជាមូលដ្ឋានសម្រាប់បែងចែកភាគលាភ និងពង្រឹងមូលនិធិរបស់ធនាគារ។

**គ. ផែនការប្រើប្រាស់ឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា**

ធនាគារ អេស៊ីលីដា បានប្រើប្រាស់ផែនការឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុ (Financial Management Tools) ផ្សេងៗ ដើម្បីធានាថាការប្រតិបត្តិការរបស់ខ្លួនមានប្រសិទ្ធភាព ស្ថិរភាព និងជៀសវាងពីហានិភ័យ។ ខាងក្រោមនេះជាឧបករណ៍សំខាន់ៗដែលធនាគារប្រើប្រាស់៖

.ផែនការប្រើប្រាស់ឧបករណ៍គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុ (Financial Information Systems – FIS) ធនាគារ អេស៊ីលីដា ប្រើប្រព័ន្ធ Core Banking System ដើម្បីគ្រប់គ្រងប្រតិបត្តិការសំខាន់ៗ ដូចជា៖

- គ្រប់គ្រងប្រាក់បញ្ញើ និងឥណទាន
- គ្រប់គ្រងការផ្ទេរប្រាក់ និងបណ្តាញ ATM
- គ្រប់គ្រងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (Financial Reporting)

ប្រព័ន្ធនេះជួយធ្វើឱ្យដំណើរការទាំងមូលមានល្បឿនលឿន ទាន់ពេល និងបង្រួមហានិភ័យ។

.Budgeting Tools ( ឧបករណ៍រៀបចំថវិកា )ធនាគារ អេស៊ីលីដា ប្រើគម្រោងថវិកា (Budget Planning Systems) ដើម្បីប៉ាន់ស្មាន និងគ្រប់គ្រង៖

- គ្រប់គ្រងប្រាក់ចំណូលនិងចំណាយប្រចាំឆ្នាំ
- គ្រប់គ្រងគោលដៅហិរញ្ញវត្ថុ
- គ្រប់គ្រងការវិភាគចំណូល-ចំណាយ និងផែនការចំណូល-ចំណាយ (Actual vs Budget)

ជួយដោះស្រាយបញ្ហាការចំណាយលើស និងធានាការប្រើប្រាស់ថវិកាដោយមានប្រសិទ្ធភាព។

.Cash Flow Management Tools (ការគ្រប់គ្រងសាច់ប្រាក់)ធនាគារ អេស៊ីលីដា តាមដានការចូលចេញនៃសាច់ប្រាក់ប្រចាំថ្ងៃ និងប្រើឧបករណ៍ដូចជា៖

- Cash Flow Forecasting Sheets
- Liquidity Monitoring Dashboards

ជួយធានាថាមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ប្រតិបត្តិការទូទៅ និងធ្វើការវិនិយោគដោយគ្មាន ហានិភ័យ។

.Risk Management Tools (ឧបករណ៍គ្រប់គ្រងហានិភ័យ) ធនាគារ អេស៊ីលីដា ប្រើប្រាស់វិធីសាស្ត្រចម្រុះដូចជា៖

- Credit Risk Models ប៉ាន់ប្រមាណហានិភ័យក្នុងការប្រគល់ឥណទាន
- Market Risk & Operational Risk Dashboards
- Loan Loss Provision Tools

ជួយព្យាករណ៍ហានិភ័យជាមុន និងទប់ស្កាត់ការបាត់បង់ទុនឱ្យអតិបរិមា។

.Financial Reporting & Analysis Software ធនាគារ អេស៊ីលីដា ប្រើប្រព័ន្ធសម្រាប់៖

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ (Income Statement, Balance Sheet, Cash Flow)
- វិភាគសមត្ថភាពនៃលទ្ធផលគ្រប់សាខា
- គណនាអត្រាដូចជា Net Interest Margin, Return on Equity, D/E Ratio ក្នុងការជួយបញ្ជូនព័ត៌មានត្រឹមត្រូវទៅកាន់អ្នកគ្រប់គ្រង និងអ្នកវិនិយោគ សរុបមក ធនាគារ អេស៊ីលីដា បានប្រើប្រាស់ឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុយ៉ាងទូលំទូលាយដើម្បី៖

- ធានាព័ត៌មានហិរញ្ញវត្ថុមានត្រឹមត្រូវ និងទាន់ពេល
- រៀបចំផែនការយុទ្ធសាស្ត្រជាក់លាក់
- ពង្រឹងសមត្ថភាពក្នុងការប្រឈមនឹងហានិភ័យ
- បង្កើនសមត្ថភាពប្រកួតប្រជែងក្នុងវិស័យធនាគារ

**ឃ. ការវាយតម្លៃប្រាក់ចំណូលដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា**

វាយតម្លៃប្រាក់ចំណូល មានន័យថា ការវាយតម្លៃ (ប៉ាន់ប្រមាណ ឬ វិភាគ) ទៅលើប្រាក់ចំណូលដែលទទួលបាន។ វាអាចប្រើបានក្នុងបរិបទជាច្រើន ដូចជា៖

- គ្រប់គ្រងផ្នែកហិរញ្ញវត្ថុ មានន័យថាការវិភាគឬប៉ាន់ប្រមាណប្រាក់ចំណូលនៃស្ថាប័ន ឬបុគ្គលក្នុងរយៈពេលជាក់លាក់ (ប្រហែលជា ១ខែ ១ឆ្នាំ ឬ ត្រីមាស)។

- គ្រប់គ្រងផ្នែកគម្រោង ឬវិនិយោគ មានន័យថា ប៉ាន់ប្រមាណប្រាក់ចំណូលដែលអាចទទួលបានពីគម្រោង ឬការវិនិយោគណាមួយ។

- គ្រប់គ្រងការរៀបចំព័ត៌មានគ្រប់គ្រង មានន័យថា ការប្រើស្ថិតិ និងទិន្នន័យដើម្បីប៉ាន់ប្រាក់ចំណូលរបស់អង្គភាពសម្រាប់កំណត់គោលដៅ និងផែនការចំណាយ។ ការវាយតម្លៃប្រាក់ចំណូលរបស់

ធនាគារ អេស៊ីលីដា (ACLEDA Bank) គឺជាដំណើរការវិភាគដើម្បីដឹងថាតើធនាគារទទួលបានប្រាក់ចំណូលប៉ុន្មានក្នុងរយៈពេលជាក់លាក់ (ឧ. ប្រចាំឆ្នាំ ឬត្រីមាស) ហើយអាចអះអាងពីស្ថានភាពហិរញ្ញវត្ថុ និងប្រសិទ្ធភាពក្នុងប្រតិបត្តិការរបស់ធនាគារ។

**ង. វាយតម្លៃចំណាយដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា**

វាយតម្លៃចំណាយរបស់ធនាគារ អេស៊ីលីដា (ACLEDA Bank) គឺជាដំណើរការវិភាគលើបំណុល និងការចំណាយដែលធនាគារបានចំណាយក្នុងការប្រតិបត្តិការរបស់ខ្លួន។ វាជាផ្នែកសំខាន់ក្នុងការវាយតម្លៃលទ្ធផលហិរញ្ញវត្ថុ និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរបស់ធនាគារ អេស៊ីលីដា ។

- **ប្រភេទចំណាយសំខាន់ៗរបស់ ធនាគារ អេស៊ីលីដា**(ACLEDA Bank)

**.ចំណាយ លើការប្រាក់** (Interest Expenses):

- បង់ការប្រាក់ឱ្យអតិថិជនលើប្រាក់បញ្ញើ
- បង់ការប្រាក់លើបំណុល ឬឧបត្ថម្ភពីធនាគារផ្សេងៗ

**.ចំណាយប្រតិបត្តិការ** (Operating Expenses):

- បៀវត្ស និងសេវាផ្សេងៗសម្រាប់បុគ្គលិក
- ចំណាយជួលអគារ ឬកន្លែងប្រតិបត្តិ
- ចំណាយលើបច្ចេកវិទ្យា (IT infrastructure)
- ថ្លៃសេវា ទឹក ភ្លើង ទូរស័ព្ទ

**.ចំណាយបង់ពន្ធ និងថ្លៃបន្ថែមផ្សេងៗ** (Tax and Other Expenses):

- ពន្ធលើប្រាក់ចំណេញ និងពន្ធដទៃទៀត
- ចំណាយផ្សេងៗទាក់ទងនឹងការគ្រប់គ្រង

**.បំណុលខាតបង់** (Loan Loss Provision):

- ចំណាយដែលគ្រប់គ្រងសម្រាប់បំណុលដែលមិនអាចប្រមូលវិញបាន
- ជាផ្នែកសំខាន់ក្នុងវិភាគហានិភ័យ

**ច. ផែនការនៃការព្យាករណ៍ពីលំហូរសាច់ប្រាក់ (Cash Flow Forecast )របស់ធនាគារ អេស៊ីលីដា**

ផែនការនៃការព្យាករណ៍ពីលំហូរសាច់ប្រាក់របស់ ធនាគារ អេស៊ីលីដា គឺជាការប៉ាន់ស្មានទិន្នន័យ ហិរញ្ញវត្ថុ ដែលបង្ហាញពីចំណូល និងចំណាយប្រាក់សុទ្ធ (សាច់ប្រាក់) ក្នុងអនាគត។ វាជាឧបករណ៍សំខាន់សម្រាប់គ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ ប្រចាំខែ ឬប្រចាំឆ្នាំ ដើម្បីធានាថាធនាគារមានប្រាក់គ្រប់គ្រាន់សម្រាប់ប្រតិបត្តិការទូទៅ និងវិនិយោគ។

**គោលបំណងនៃផែនការនៃការព្យាករណ៍ពីលំហូរសាច់ប្រាក់ Cash Flow Forecast**

- ប៉ាន់ស្មានចំណូលសាច់ប្រាក់ (cash inflow) និងចំណាយសាច់ប្រាក់ (cash outflow)
- កំណត់សមតុល្យសាច់ប្រាក់ (cash balance)
- ជួយធានាថាមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ប្រតិបត្តិការទូទៅ

- រៀបចំផែនការវិនិយោគ ឬចំណាយបន្ថែមដោយគ្មានហានិភ័យខ្វះសាច់ប្រាក់

**ឆ. ការគ្រប់គ្រងបំណុល និងទុនអាជីវកម្មរបស់ធនាគារ អេស៊ីលីដា**

ការគ្រប់គ្រងបំណុល (liabilities/debt) និងទុនអាជីវកម្ម (equity/capital) គឺជាផ្នែកសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ។ វាជួយធានាថាធនាគារមានសមត្ថភាពលើសមតុល្យហិរញ្ញវត្ថុ មានសភាព រឹងមាំក្នុងការប្រតិបត្តិ និងអាចប្រឈមនឹងហានិភ័យនៅក្នុងវិស័យហិរញ្ញវត្ថុបានយ៉ាងប្រសើរ។

**.**ការគ្រប់គ្រងបំណុល (Debt Management) ធនាគារ អេស៊ីលីដា មានការគ្រប់គ្រងបំណុលដោយផ្អែកលើសមត្ថភាពបង់ប្រាក់ និងមានប្រសិទ្ធភាពនៃប្រភពហិរញ្ញវត្ថុ។ បំណុលរបស់ធនាគារមានពីប្រភពដូចជា៖

❖ **ប្រភេទបំណុល**

- ប្រាក់បញ្ញើរបស់អតិថិជន (Customer Deposits)։ ប្រភពសំខាន់សម្រាប់បណ្តាញឥណទាន
- បំណុលពីធនាគារផ្សេងៗ(Interbank Borrowings)៖ បើមានការបង្ហាញស្រាលសាច់ប្រាក់ ឬការប្រើប្រាស់ធនធានបន្ថែម។
- បំណុលសាធារណៈ( Subordinated Debt)៖ ឧបត្ថម្ភឥណទានរយៈពេលវែងពីស្ថាប័នរដ្ឋ ឬអន្តរជាតិ គោលដៅនៃការគ្រប់គ្រងបំណុល។
- បង្កើនសមត្ថភាពផ្តល់ឥណទាន
- រក្សាសុវត្ថិភាពក្នុងការបង់ត្រឡប់
- កាត់បន្ថយតម្លៃហិរញ្ញវត្ថុ
- គ្រប់គ្រងអត្រាបំណុល/ទុន (Debt to Equity Ratio)

.ការគ្រប់គ្រងទុនអាជីវកម្ម (Capital Management) ទុនអាជីវកម្មរបស់ ធនាគារ អេស៊ីលីដា ជាទុនដែលធនាគារប្រើសម្រាប់ការប្រតិបត្តិ និងការវិនិយោគ ដើម្បីបង្កើនប្រាក់ចំណូល។ ទុននេះមកពី៖

❖ **ប្រភពទុន**

- ទុនចាប់ផ្តើម (Initial Capital)៖ ទុនដែលបានវិនិយោគដំបូង
- ប្រាក់ចំណេញដែលរក្សាទុក (Retained Earnings)៖ ចំណេញដែលមិនចែកជាភាគលាភ
- ការលក់ភាគហ៊ុន (Shareholder Equity)៖ ការវិនិយោគពីអ្នកបង្កើត ឬភាគីទីបី

**គោលដៅនៃការគ្រប់គ្រងទុន**

- រក្សាស្ថិរភាពហិរញ្ញវត្ថុ
- ធានាការប្រកួតប្រជែងក្នុងវិស័យធនាគារ
- ប្រកាន់ខ្ជាប់តាមលក្ខខណ្ឌនៃ Basel Accords ( ការអនុវត្តន៍កម្រិតទុនអប្បបរមា )
- ប្រើទុនឱ្យមានប្រសិទ្ធភាព ដោយវិនិយោគទៅលើឥណទាន ឬគម្រោងចំណូលខ្ពស់

.សមតុល្យរវាងបំណុលនិងទុន (Debt-to-Equity Balance)សមតុល្យរវាងបំណុល និងទុន (Debt-to-Equity Balance) គឺជាសូចនាករហិរញ្ញវត្ថុសំខាន់មួយ ដែលធនាគារប្រើសម្រាប់វាយតម្លៃលើស្ថានភាពហិរញ្ញវត្ថុ និងសមត្ថភាពគ្រប់គ្រងហានិភ័យរបស់ខ្លួន។ សូចនាករនេះ បង្ហាញពីចំនួនប្រាក់បំណុលដែលធនាគារប្រើប្រាស់ បើប្រៀបធៀបនឹងទុនសម្ភារៈ (Equity Capital) របស់ខ្លួន។ អត្រាបំណុល និងទុននេះមានសារៈសំខាន់ក្នុងការត្រួតពិនិត្យថា ស្ថាប័នណាមួយមានបំណុលខ្ពស់ជាងទុនរបស់ខ្លួនឬទេដែលប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

សម្រាប់ធនាគារ អេស៊ីលីដា ដែលជាធនាគារនាំមុខនៅប្រទេសកម្ពុជា មានប្រវត្តិក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុយ៉ាងសកម្ម ការរក្សាសមតុល្យរវាងបំណុលនិងទុន គឺជាគន្លងយុទ្ធសាស្ត្រសំខាន់ក្នុងការជួយបង្កើនសមត្ថភាពផ្តល់កម្ចី និងបង្កើតប្រាក់ចំណេញ ដើម្បីធានាថាធនាគារអាចរីកចម្រើន និងមានស្ថិរភាពហិរញ្ញវត្ថុចំពោះការប្រឈមមុខនឹងហានិភ័យផ្សេងៗ។

**ជ. ការត្រួតពិនិត្យ និងវាយតម្លៃការរៀបចំរបាយការណ៍ប្រចាំខែ/ត្រីមាសរបស់ធនាគារ អេស៊ីលីដា**

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ និងត្រីមាស ជាផ្នែកមួយនៃការគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុ និងស្ថិរភាពនៃធនាគារ។ ធនាគារ អេស៊ីលីដា ត្រូវរៀបចំរបាយការណ៍ទាំងនេះដើម្បីបំពេញតាមលក្ខខណ្ឌរបស់ ធនាគារជាតិនៃកម្ពុជា និងដើម្បីរក្សាការគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែប្រសើរ។

❖ គោលបំណងនៃការត្រួតពិនិត្យនិងវាយតម្លៃរបាយការណ៍

- ពិនិត្យភាពត្រឹមត្រូវនៃទិន្នន័យហិរញ្ញវត្ថុ
- វាយតម្លៃលទ្ធផលប្រតិបត្តិប្រចាំខែ/ត្រីមាស
- ជួយគ្រប់គ្រងស្ថានភាពសាច់ប្រាក់ និងឥណទាន
- បញ្ជូនព័ត៌មានទៅស្ថាប័នជាប់ពាក់ព័ន្ធ (NBC, អ្នកវិនិយោគ, អ្នកគ្រប់គ្រងខាងលើ)

## ៣.៣ ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពមានសារៈសំខាន់សម្រាប់ធនាគារ អេស៊ីលីដា

ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ធនាគារ អេស៊ីលីដា ដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ ការបំពេញផែនការអាជីវកម្ម ការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ ផ្តល់ជាភាពងាយស្រួលក្នុងការអនុវត្តន៍គោលនយោបាយ គាំទ្រដល់ការសម្រេចផែនការយុទ្ធសាស្ត្រ ដែលជាភាពរីកចម្រើនរបស់ធនាគារចង់បាន។ ខាងក្រោមនេះជាសារៈសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព៖

### ៣.៣.១ ប្រសិទ្ធភាពនៃការធានាបាននូវស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា

ប្រសិទ្ធភាពនៃការធានាបាននូវស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា អាចគ្រប់គ្រងចំណូលចំណាយ បំណុល និងរក្សាបានធនធានយ៉ាងល្អប្រសើរ ដោយរក្សាគុណភាពសេវាកម្ម អាចប្រើប្រាស់ធនធាន

បានយ៉ាងត្រឹមត្រូវទទួលបានទំនុកចិត្តពីភាគីពាក់ព័ន្ធ ជៀសវាងការប្រឈមនឹងហានិភ័យ ជួយអភិវឌ្ឍន៍យុទ្ធសាស្ត្រអាជីវកម្មរក្សាហិរញ្ញវត្ថុប្រចាំឆ្នាំ ការវិភាគសមត្ថភាពសាច់ប្រាក់ (Cash Flow Analysis) និងថវិកាប្រកបដោយប្រសិទ្ធភាព ដើម្បីរក្សាទំនាក់ទំនងជាមួយអតិថិជន ប្រតិបត្តិការបានល្អ និងការរីកចម្រើនដ៏ប្រសើរ។

- **ធានាស្ថិរភាពហិរញ្ញវត្ថុ** ក្នុងការគ្រប់គ្រងលើប្រាក់ចំណូល ចំណាយ និងទិន្នន័យហិរញ្ញវត្ថុយ៉ាង ត្រឹមត្រូវជួយឱ្យធនាគារអាចមានសមតុល្យក្នុងការប្រើប្រាស់ធនធាន ហើយទប់ស្កាត់ហានិភ័យសេដ្ឋកិច្ចក្នុងអនាគត។
- **បង្កើនចំណូល និងកាត់បន្ថយចំណាយ** ការគ្រប់គ្រងប្រាក់ចំណូល និងចំណាយយ៉ាងប្រក្រតីជួយឱ្យធនាគារបង្កើនកម្រិតចំណេញ និងកាត់បន្ថយថវិកាដែលមិនចាំបាច់មួយចំនួន។
- **ជួយដល់ការធ្វើផែនការយុទ្ធសាស្ត្រឱ្យប្រសើរឡើង** ដោយមានទិន្នន័យហិរញ្ញវត្ថុច្បាស់លាស់ ធនាគារ អេស៊ីលីដា អាចវាយតម្លៃស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួន ហើយបង្កើតផែនការផ្សេងៗ ដើម្បីដោះស្រាយបញ្ហា ឬពង្រីងទីផ្សារបានល្អ។
- **ការប្រកួតប្រជែងនៅក្នុង ទី ផ្សារ** ធនាគារដែលមានស្ថិរភាពហិរញ្ញវត្ថុនឹងមានសមត្ថភាពប្រកួតប្រជែងមួយដៃគូអាជីវកម្ម ដោយសារតែសមត្ថភាពផ្តល់សេវាជូនអតិថិជនបានល្អជាង។
- **បង្កើនសមត្ថភាពប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃ** ប្រសិទ្ធភាពក្នុងការគ្រប់គ្រងផលប្រយោជន៍ ហិរញ្ញវត្ថុអាចជួយឱ្យធនាគារមានដំណើរការប្រតិបត្តិការបានល្អមានសាច់ប្រាក់គ្រប់គ្រាន់ ក្នុងការបំពេញសេវាដល់អតិថិជន និងដោះស្រាយបញ្ហាផ្សេងៗ។
- **បង្កើតភាពជឿជាក់ជាមួយអតិថិជន និងអ្នកវិនិយោគ** ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពមានសារៈសំខាន់ណាស់សម្រាប់អ្នកវិនិយោគ និងអតិថិជននឹងមានជំនឿចិត្តចំពោះធនាគារ។ ជាក់ស្តែងធនាគារ អេស៊ីលីដា អាចទាក់ទាញអតិថិជនថ្មីជាច្រើន និងរក្សាអតិថិជនចាស់បានល្អ។ ធនាគារ អេស៊ីលីដា ដែលបម្រើអតិថិជនជាច្រើនទូទាំងប្រទេស ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព គឺជាចំណុចស្នូលក្នុងការធានាស្ថិរភាពហិរញ្ញវត្ថុ និងការរីកចម្រើនបន្តរបសធនាគារ។

### ៣.៣.២ ប្រសិទ្ធភាពនៃការធ្វើផែនការរបស់ធនាគារ អេស៊ីលីដា (ACLEDA Bank)

ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធ្វើផែនការ ពីព្រោះវាជាមូលដ្ឋានសំខាន់សម្រាប់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងជួយឱ្យធនាគារអភិវឌ្ឍប្រកបដោយចីរភាព។

- **ជួយកំណត់ផែនការហិរញ្ញវត្ថុ** ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពមានសារៈសំខាន់អាចកំណត់បានថាវិធីណាសាស្ត្រ និងបរិមាណធនធានដែលត្រូវប្រើប្រាស់ក្នុងការសម្រេចផែនការ។ ម្យ៉ាងទៀតធនាគារ អេស៊ីលីដា អាចកំណត់ផែនការពង្រីកការវិនិយោគ ដោយត្រូវការប្រើហិរញ្ញវត្ថុប៉ុន្មាន ទំហំប្រតិបត្តិការ និងបច្ចេកវិទ្យាថ្មីៗ។

- **ផ្តល់មូលដ្ឋានសម្រាប់ការធ្វើផែនការអាជីវកម្ម** ផែនការហិរញ្ញវត្ថុមានចំណុចមូលដ្ឋានសម្រាប់ការរៀបចំផែនការប្រចាំខែ ប្រចាំឆ្នាំ និងវឌ្ឍនភាពយុទ្ធសាស្រ្តអនាគត។ ធនាគារ អាចកំណត់ថវិកាសម្រាប់គម្រោងអភិវឌ្ឍន៍ថ្មីៗ ( ឧ. Mobile Banking) និងផែនការពង្រីកសេវាធានាថានឹងមានថវិកាគ្រប់គ្រាន់។
- **ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន** ជាការគ្រប់គ្រងប្រសិទ្ធភាព ដើម្បីបានធានាថាការចំណាយនីមួយៗនាំឱ្យមានផលចំណេញ។ ធនាគារ អេស៊ីលីដា ក៏អាចកាត់បន្ថយចំណាយលើផ្នែកណាមួយដែលមិនចាំបាច់ និងធ្វើការវិនិយោគលើបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនសេវាកម្មឱ្យប្រសើរឡើង។
- **ការកាត់បន្ថយហានិភ័យក្នុងការធ្វើផែនការ** ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុបានល្អអាចធ្វើឱ្យធនាគារអាចប៉ាន់ប្រមាណពីហានិភ័យដូចជា បំណុលអតិថិជនមិនបង់ ឬបញ្ហាសាច់ប្រាក់ខ្វះខាត។ ជាមួយគ្នានេះដែរធនាគារ អេស៊ីលីដា អាចដាក់គោលនយោបាយសម្រាប់វាយតម្លៃហានិភ័យ និងត្រួតពិនិត្យប្រតិបត្តិការ ជាប្រចាំ ដើម្បីត្រៀមខ្លួនជាមុនក្នុងការជួយកាត់បន្ថយការខាតបង់ហិរញ្ញវត្ថុ និងធានាស្ថិរភាពរបស់ធនាគារ។
- **បង្កើនភាពជឿជាក់នៃការធ្វើផែនការ** ការគ្រប់គ្រងល្អបង្ហាញថាធនាគារមានសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងអនុវត្តផែនការ។ ដើម្បីបង្កើតភាពជឿជាក់ដល់ភាគីពាក់ព័ន្ធដូចជាអតិថិជន អ្នកវិនិយោគ និងដៃគូអាជីវកម្ម។
- **ការអភិវឌ្ឍន៍ប្រកបដោយចីរភាព** ការគ្រប់គ្រងហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពធានាថាថវិកាអាចប្រាស់សម្រាប់ការវិនិយោគ និងបង្កើនប្រាក់ចំណេញ។ ធនាគារ អេស៊ីលីដា សម្រេចបាននូវផែនការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានស្ថិរភាព និងដំណើរការក្នុងទីផ្សារផងដែរ។

**៣.៣.៣ ប្រសិទ្ធភាពនៃការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា**

ប្រសិទ្ធភាពនៃការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា (ACLEDA Bank) ជាជំហានសំខាន់ក្នុងការពង្រឹងស្ថិរភាព និងភាពជឿជាក់លើការអភិវឌ្ឍន៍របស់ធនាគារ។

- **ការរៀបចំផែនការហិរញ្ញវត្ថុ** ជាការរៀបចំផែនការចំណូល និងចំណាយជាដំណើរការមួយដែលជួយឱ្យធនាគារអាចបែងចែកធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព ក្នុងការរៀបចំគម្រោងផ្តល់ប្រាក់កម្ចីត្រូវការថវិកាច្រើន បន្ទាប់ពីមានផែនការគេអាចប្រើវាជាឧបករណ៍ត្រួតពិនិត្យ (monitoring tool) ដើម្បីមើលថាតើប្រាក់ត្រូវបានប្រើត្រឹមត្រូវឬអត់ ?
- **ការតាមដាន និងវាយតម្លៃលើហានិភ័យហិរញ្ញវត្ថុ** ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អអាចជួយឱ្យធនាគារ អេស៊ីលីដា អាចវិភាគពីហានិភ័យបានជាមុនដូចជា អតិថិជនដែលមាន ឥណទានខ្ពស់ ការបន្ថយប្រាក់ចំណេញ ស្ថានភាពទីផ្សារមិនស្ថិរភាព។ អ្នកគ្រប់គ្រងអាចចាត់វិធានការបង្ការ ឬរៀបចំសម្រួលលើការវិនិយោគឡើងវិញ ដើម្បីកាត់បន្ថយផលប៉ះពាល់ហិរញ្ញវត្ថុ។ ប្រសិនបើសាខាមួយមានបំណុលមិនអាចប្រមូលបាន នោះត្រូវដាក់គោលនយោបាយវាយតម្លៃឥណទានសាខាឡើងវិញ។

- **ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ** ការគ្រប់គ្រងហិរញ្ញវត្ថុល្អធានាបានថាត្រូវប្រើប្រាស់ហិរញ្ញវត្ថុដោយទទួលបានតម្លៃខ្ពស់បំផុត (maximize return)។ ក្នុងការវិនិយោគលើ បច្ចេកវិទ្យាថ្មីសម្រាប់ Mobile Banking អាចបង្កើនសេវាកម្មជូនដល់អតិថិជនបានលឿន ហើយអាចកាត់បន្ថយចំណាយលើការប្រើប្រាស់បុគ្គលិកផងដែរ។ ប្រសិនបើការគ្រប់គ្រងធនធានហិរញ្ញវត្ថុមិនត្រឹមត្រូវនឹងបណ្តាលឱ្យបាត់បង់ប្រាក់ ឬមានហានិភ័យពីការប្រតិបត្តិខុស។
- **ការការពារក្នុងស្ថានភាពវិបត្តិហិរញ្ញវត្ថុ** ការរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុល្អជួយបង្កើតធនធានបម្រុងសម្រាប់ទប់ស្កាត់ក្នុងស្ថានភាពប្រញាប់ប្រញាល់ និងករណីដែលអតិថិជនដកប្រាក់ច្រើនក្នុងពេលតែមួយបាន ប្រសិនបើគ្មានការគ្រប់គ្រងល្អអាចនាំឱ្យបាត់បង់ជំនឿទុកចិត្ត និងបង្កជាបញ្ហាទាំងក្នុង និងក្រៅធនាគារ។
- **ការធានាស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង** ការគ្រប់គ្រងហិរញ្ញវត្ថុជាលក្ខណៈប្រព័ន្ធ (Systematic Financial Management) អាចធានាឱ្យធនាគាររីកចម្រើន និងមានស្ថិរភាព។ ប្រសិនបើធនាគារមានផែនការបង្កើនសេវាកម្មឌីជីថលក្នុងរយៈ៥ឆ្នាំត្រូវគ្រប់គ្រងថវិកាដោយការរៀបចំគោលយោបាយវិនិយោគ និងថែរក្សាឥណទាន ដើម្បីធានាបានថាធនាគារមានសមត្ថភាពក្នុងការអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រដោយគ្មានភាពរអាក់រអួលលើហានិភ័យហិរញ្ញវត្ថុ។

**៣.៣.៤ ប្រសិទ្ធភាពនៃការសម្រេចផែនការ និងអនុវត្តគោលនយោបាយល្អរបស់ធនាគារ អេស៊ីលីដា**

ប្រសិទ្ធភាពនៃការសម្រេចផែនការ និងអនុវត្តគោលនយោបាយបានរបស់ធនាគារ អេស៊ីលីដា ជាមូលដ្ឋានសំខាន់ក្នុងការធានាថាសកម្មភាពទាំងអស់ត្រូវបានអនុវត្តឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

- **ផ្តល់ជាមូលដ្ឋានក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ** ការប្រមូលទិន្នន័យហិរញ្ញវត្ថុ (របាយការណ៍ចំណូល ចំណាយ ស្ថានភាពសាច់ប្រាក់) ដែលធ្វើឱ្យអ្នកគ្រប់គ្រងអាចត្រួតពិនិត្យ និងសម្រេចចិត្តលើផែនការសំខាន់ៗជាមុន នៅក្នុងការម្រេចចិត្ត ការប៉ាន់ស្មានថវិកា និងវិភាគផលប៉ះពាល់ដល់ផ្នែកហិរញ្ញវត្ថុ។ ដើម្បីជៀសវាងការសម្រេចចិត្តមិនត្រឹមត្រូវ ឬធ្វើឱ្យបាត់បង់ធនធានហិរញ្ញវត្ថុ។
- **អនុវត្តគោលនយោបាយបានប្រសិទ្ធភាព** ការអនុត្តន៍លើគោលនយោបាយរបស់ធនាគារដូចជា ការផ្តល់ប្រាក់កម្ចីដល់អតិថិជនខ្នាតតូច ការចូលរួមជាមួយបណ្តាញអនឡាញ និងសេវាធនាគារឌីជីថលធនាគារត្រូវការថវិកា និងការគ្រប់គ្រងសាច់ប្រាក់ឱ្យបានច្បាស់លាស់។ ប្រសិនបើគោលនយោបាយជំរុញឱ្យធនាគារឌីជីថលត្រូវវិនិយោគលើបច្ចេកវិទ្យាថ្មីៗ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុទទួលបានប្រសិទ្ធភាព។
- **តាមដាន និងវាយតម្លៃលទ្ធផលនៃគោលនយោបាយ** ដោយមានការគ្រប់គ្រងហិរញ្ញវត្ថុច្បាស់លាស់អ្នកគ្រប់គ្រងអាចធ្វើបច្ចុប្បន្នភាព និងវាយតម្លៃលើគម្រោងដែលអនុវត្ត។ ប្រសិនបើគម្រោងក្នុងជំរុញការប្រើ App Mobile Banking មិនបានសម្រេចជាលទ្ធផលអ្នកគ្រប់គ្រងអាចវិភាគថវិកា

បរិមាណអ្នកប្រើប្រាស់ និងចំណាយផ្សេងៗ ដើម្បីជួយឱ្យធនាគារមានការកែសម្រួលទៅលើគោលនយោបាយឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពជាក់ស្តែង។

- **បង្កើតភាពជឿជាក់ក្នុងការទាក់ទងនឹងភាគីក្រៅ** ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អបង្ហាញពីសមត្ថភាពរបស់ធនាគារ អេស៊ីលីដា ក្នុងការទាក់ទាញអ្នកវិនិយោគមកបណ្តាក់ទុន។ ជាពិសេសធនាគារ អេស៊ីលីដា ជាធនាគារធំ មានភាគីចូលរួមជាច្រើនរួមទាំងអតិថិជន និងបណ្តាញអន្តរជាតិ។
- **ការសម្រេចផែនការយុទ្ធសាស្ត្រ** ផែនការយុទ្ធសាស្ត្ររបស់ធនាគារ អេស៊ីលីដា ត្រូវបានដំណើរការយ៉ាងស៊ីជម្រៅដូចជា ការអភិវឌ្ឍន៍លើបុគ្គលិក ការអភិវឌ្ឍន៍លើបច្ចេកវិទ្យា និងការផ្តល់សេវាផ្សេងៗ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រើប្រាស់។ ដើម្បីសម្រេចផែនការនេះបានត្រូវមានថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុរឹងមាំ។ ប្រសិនបើផែនការរបស់ធនាគារ គឺក្លាយជាអ្នកដឹកនាំផ្នែកសេវាឌីជីថល ធនាគារត្រូវចំណាយលើ Training Software, Infrastructure តម្រូវឱ្យមានការគ្រប់គ្រងយ៉ាងច្បាស់លាស់។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទស្តីពី ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាម៉ៅសេទុង កន្លងមកបានធ្វើឱ្យ ក្រុមនាងខ្ញុំបានរកឃើញពីចំណុចខ្លាំង និងសក្តានុពលរបស់ធនាគារ អេស៊ីលីដា ដែលមានដូចជា៖

- មានការកំណត់ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ដែលជាមូលដ្ឋានសំខាន់ដើម្បីធានាបាននូវគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុ សម្រេចគោលដៅហិរញ្ញវត្ថុ គ្រប់គ្រងប្រាក់ចំណូលចំណាយឱ្យមានប្រសិទ្ធភាព និងការរីកចម្រើនយ៉ាងត្រឹមត្រូវនាពេលអនាគត។
- ការរៀបចំគម្រោងផែនការថវិការបស់ធនាគារ អេស៊ីលីដា គឺជាដំណើរការសំខាន់ក្នុងការគ្រប់គ្រងបែកចែកថវិកា ឬការគ្រប់គ្រងប្រាក់ចំណាយ និងប្រាក់ចំណូលមានប្រសិទ្ធភាព និងជៀសវាងការបាត់បង់ធនធាន និងធ្វើការព្យាករណ៍ពីលំហូរសាច់ប្រាក់បានហើយជាជំហានមុននៃការសម្រេចចិត្ត។
- មានផែនការប្រើប្រាស់ឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ ដើម្បីប្រាកដថាប្រតិបត្តិការរបស់ខ្លួនមានប្រសិទ្ធភាព។
- ការកំណត់ផែនការថវិកាផ្តល់សារៈសំខាន់ខ្លាំងក្នុងការបញ្ចៀសនូវហានិភ័យផ្សេងៗ និងធានាបាននូវស្ថិរភាពហិរញ្ញវត្ថុដល់ធនាគារ។
- ការសម្រេចផែនការ និងអនុវត្តគោលនយោបាយបានល្អ ជាមូលដ្ឋានសំខាន់ក្នុងការធានាថាសកម្មភាពទាំងអស់ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ និងល្អប្រសើរ។
- ការធានានូវស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា បានផ្តល់នូវប្រសិទ្ធភាពហិរញ្ញវត្ថុរបស់ខ្លួនក្នុងការរក្សាទំនុកចិត្តពីអតិថិជន និងអ្នកវិនិយោគ។
- ការត្រួតពិនិត្យ និងវាយតម្លៃការរៀបចំរបាយការណ៍ប្រចាំខែរបស់ធនាគារ អេស៊ីលីដា ជាផ្នែកមួយនៃការគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុឱ្យមានស្ថិរភាព។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជាធនាគារ អេស៊ីលីដា ទទួលបានជោគជ័យទៅលើដំណើរការសេវាកម្មរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ធនាគារនៅតែមានចំណុចខ្វះខាតមួយចំនួនដែលមិនទាន់បានបំពេញទាំងស្រុងនៅឡើយ។ ទន្ទឹមនឹងចំណុចខ្លាំង ដែលបានរៀបរាប់ខាងលើ យើងសង្កេតឃើញថាធនាគារអេស៊ីលីដា ក៏មានចំណុចខ្សោយមួយចំនួនតូចផងដែរមាន ដូចជា៖

- ការវាយតម្លៃប្រាក់ចំណូលដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ឃើញថាធ្វើឡើងតាមការប៉ាន់ស្មាន ឬវិភាគដោយមិនបានមានបច្ចេកវិទ្យាគ្រប់គ្រាន់ ហេតុនេះទិន្នន័យដែលទទួលបានវាមិនពិតទាំងស្រុងនាំឱ្យប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចផ្នែកគ្រប់គ្រងហរិញ្ញវត្ថុ និងការធ្វើផែនការហរិញ្ញវត្ថុ។

- ការវាយតម្លៃប្រាក់ចំណាយដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា យើងឃើញថា នៅពេលអនុវត្តខ្វះការគ្រប់គ្រង តាមដានទៅលើចំណាយការប្រាក់ ចំណាយប្រតិបត្តិការ និងការបង់ពន្ធផ្សេងៗ។
- ការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ ដោយមានប្រើប្រាស់បច្ចេកវិទ្យាតាមរយៈ Mobile Banking ធ្វើឱ្យមានហានិភ័យសន្តិសុខ (Security Risks) តាមការរយៈលួចសាច់ប្រាក់នៅក្នុងគណនី (hacking) និងប្រព័ន្ធរអាក់រអួល(Error System)។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគយ៉ាងលម្អិតអំពីផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាម៉ៅសេទុង ក្រុមនាងខ្ញុំអាចសន្និដ្ឋានបានថា ការគ្រប់គ្រងហិរញ្ញវត្ថុមានតួនាទីសំខាន់យ៉ាងខ្លាំងក្នុងការធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ ការសម្រេចគោលដៅយុទ្ធសាស្ត្រ និងការរីកចម្រើនប្រកបដោយចីរភាពរបស់ធនាគារ។ ធនាគារ អេស៊ីលីដា បានអនុវត្តផែនការគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព ដោយមានការកំណត់គោលដៅថវិកា ការរៀបចំបច្ចេកទេសក្នុងការវាយតម្លៃប្រាក់ចំណូល-ចំណាយ ការព្យាករណ៍ពីលំហូរសាច់ប្រាក់ ការត្រួតពិនិត្យលទ្ធផល និងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងឌីជីថល ដើម្បីជួយកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចដាក់លាក់ក្នុងការគ្រប់គ្រងធនធាន។ លើសពីនេះ ធនាគារ អេស៊ីលីដា ក៏បានពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យ ដោយមានប្រព័ន្ធវាយតម្លៃ ហានិភ័យ បំណុល និងប្រកពទុនយ៉ាងច្បាស់លាស់។ ផែនការហិរញ្ញវត្ថុនេះអាចទាក់ទាញ ភាគីពាក់ព័ន្ធ អ្នកវិនិយោគ និងអតិថិជនដោយបង្កើតទំនុកចិត្ត និងភាពជឿជាក់លើសមត្ថភាពគ្រប់គ្រងរបស់ធនាគារ។ ដោយសារតែការគ្រប់គ្រងហិរញ្ញវត្ថុមានប្រសិទ្ធភាពបានធ្វើឱ្យ ធនាគារ អេស៊ីលីដា ស្ថិតក្នុងស្ថានភាពរឹងមាំ ប្រកួតប្រជែងបានជាមួយស្ថាប័នសេដ្ឋកិច្ចផ្សេងៗ និងអាចទទួលស្គាល់ជាធនាគារដែលមានសមត្ថភាពនាំមុខនៅក្នុង វិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ទោះបីជា ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យក្នុងការអភិវឌ្ឍន៍ដំណើរការគ្រប់គ្រងសេវាកម្មរបស់ខ្លួនក៏ដោយ ក៏ធនាគារគួរតែកែសម្រួល និងកែលម្អបន្ថែមលើចំណុចមួយចំនួនដូចជា ការបណ្តុះបណ្តាលបុគ្គលិក ការត្រួតពិនិត្យថវិកា ការគ្រប់គ្រងហានិភ័យ និងការប្រើប្រាស់បច្ចេកវិទ្យា។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្វែងយល់ យ៉ាងលម្អិតអំពីលទ្ធផលនៃការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំ លើដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាម៉ៅសេទុង ក្រុមនាងខ្ញុំបានរកឃើញពី ចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ។ ជាមួយគ្នានេះផងដែរ ក្រុមរបស់នាងខ្ញុំក៏មានមតិមួយចំនួនដើម្បីជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា កាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ធនាគារគួរតែកែលម្អនៅចំណុចខ្វះខាតមួយចំនួនដូចខាងក្រោមៈ

- ក្នុងការវាយតម្លៃប្រាក់ចំណូលដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ត្រូវធ្វើការកែលម្អទៅការវិភាគទិន្នន័យតាមការប៉ាន់ស្មាន ដោយប្រើប្រាស់ system តែមួយមកវិភាគវិញ និងបង្កើតជាសិនណារីយ៉ូ (Scenario analysis) និងត្រួតពិនិត្យពីរបាយការណ៍សាច់ប្រាក់ជាប្រចាំ។

- ការវាយតម្លៃចំណាយដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់គួរតែ បង្កើតប្រព័ន្ធតាមដាននៅក្នុងដំណើរការអនុវត្តន៍នីតិវិធីក្នុងការវាយតម្លៃជាប្រចាំទៅលើប្រភេទចំណាយសំខាន់ៗ ដូចជាចំណាយលើការប្រាក់ ចំណាយប្រតិបត្តិការ ចំណាយបង់ពន្ធ និងចំណាយបន្ថែមផ្សេងៗ។
- ការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ ដោយមានប្រើប្រាស់បច្ចេកវិទ្យាតាមរយៈ Mobile Banking គួរតែមានការកែលម្អបន្ថែមទៅលើចំណុចមួយចំនួនដើម្បីបង្កើនសុវត្ថិភាពបច្ចេកវិទ្យា ដោយមានប្រើប្រាស់ Two-factor authentication (2FA), Face ID, Encryption, និង Firewall ផ្តល់ Video, Posters, Training materials ស្តីពីរបៀបប្រើ Mobile Banking និងដើម្បីការពារខ្លួនពីការលួចទិន្នន័យ។

# ឯកសារយោង

## សៀវភៅ


1. រៀបរៀងដោយនិស្សិតឈ្មោះ ជា សុភាព, ថាយ ចិន្តា, នាក់ ស្រីយា, យ៉េត ម៉េងស្រ៊ឹម. (២០២២) ប្រធានបទ៖ *ការគ្រប់គ្រងសាច់ប្រាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាផ្សារដើមថ្កូវ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០ នៃវិទ្យស្ថាន វ៉ាន់ដា. ៤០ទំព័រ. ភ្នំពេញ។
2. រៀបរៀងដោយនិស្សិតឈ្មោះ ពុន ស្រីម៉ី, សាក់ លីហ្សា, ហួង ស្រីហួច, ស៊ីម ស្រីអន, ឡឿន ដារី. (២០២១). ប្រធានបទ៖ *ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី សាខាម៉ៅសេទុង.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី១៩ នៃវិទ្យស្ថាន វ៉ាន់ដា. ៤៥ទំព័រ. ភ្នំពេញ។
3. រៀបរៀងដោយនិស្សិតឈ្មោះ ហៀក ឈាន, សំរិត ស្រីមុំ, ធុន ចាន់រតនា, អ៊ុង លីដា. ប្រធានបទ៖ *ការគ្រប់គ្រងចំណូលរបស់ធនាគារ អេស៊ីលី ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី១៩ នៃវិទ្យស្ថាន វ៉ាន់ដា. ៣៥ទំព័រ. ភ្នំពេញ។
4. Mishkin, F. S. (2019). *The Economics of Money, Banking, and Financial Markets* (12th ed.). Pearson.
5. Brealey, R. A., Myers, S. C., & Allen, F. (2020). *Principles of Corporate Finance* (13th ed.). McGraw-Hill Education.


## គេហទំព័រផ្សេងៗ


1. របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ធនាគារ អេស៊ីលីដា Retrieved May 07 2025 from https://www.acledabank.com.kh
2. WordPress. Sokankeng. (2021, June 10). *និយមន័យការគ្រប់គ្រង.* Retrieved May 07 2025 from https://sokankeng.wordpress.com
3. Scribd. (2021, June 10). *និយមន័យការគ្រប់គ្រង.* Retrieved from https://www.scribd.com
4. FHSU Digital Press. Pressbooks. (2019, March, 21) *ប្រវត្តិនៃការគ្រប់គ្រង.* Retrieved May 07 2025 from https://fhsu.pressbooks.pub
5. Wikipedia. (2018, April 25). *និយមន័យហិរញ្ញវត្ថុ.* Retrieved May 07 2025 from https://km.wikipedia.org/wiki
6. WordPress. Khem Sarith. (2016, October 04) *និយមន័យធនាគារ.* Retrieved May 07 2025 from https://khemsarith.wordpress.com

# ឧបសម្ព័ន្ធ




ធនាគារ អេស៊ីលីដា សាខាម៉ៅសេទុង




ធនាគារ អេស៊ីលីដាៈ របាយការណ៍ប្រចាំឆ្នាំ ២០២៣



## គុណតម្លៃ

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារខ្មែរ ធ្វើប្រតិបត្តិការនៅក្នុងប្រទេសដូចជា កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលប្តេជ្ញា និងរក្សាគុណតម្លៃរបស់ខ្លួន ជាមួយនឹងស្ថិរភាពហិរញ្ញវត្ថុ សុវត្ថិភាព សមត្ថភាព សុចរិតភាព គណនេយ្យភាព តម្លាភាព ភាពស្មោះត្រង់ បរិសុទ្ធ និងការយល់ចិត្ត។ តម្លៃទាំងនេះត្រូវបានកំណត់យ៉ាងច្បាស់ក្នុងអត្ថន័យនៃអក្សរជាភាសាខ្មែរ-អង់គ្លេស "អ-A, ស-C, ល-L, ដ-D (**អេស៊ីលីដា**-ACLEDA)"។

**អ** អភិសមាចារ — ធនាគារផ្តោតលើការប្រព្រឹត្តរៀបរយគួរឱ្យពេញចិត្ត គួរឱ្យជ្រះថ្លាដល់គ្រប់ភាគី រួមមានបុគ្គលិក អតិថិជន ដៃគូរអាជីវកម្ម និងសាធារណជនទូទៅ។

**ស** សុចរិតភាព ស្មោះត្រង់ — ធនាគារផ្តោតលើការបម្រើសេវាកម្មជូនអតិថិជន សាធារណជន ប្រកបដោយសេចក្តីសុចរិត និងក្រមសីលធម៌វិជ្ជាជីវៈ។

**ល** លឿនទាន់ចិត្ត លទ្ធផលល្អ — ធនាគារផ្តោតលើការបម្រើរហ័សទាន់ចិត្ត ផ្គាប់ចិត្ត ផ្តល់នូវទំនុកចិត្តខ្ពស់ជូនអតិថិជន-សាធារណជនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលល្អ។

**ដ** ដុះដាលថ្កើងថ្កាន — ធនាគារផ្តោតលើការអភិវឌ្ឍគំនិតច្នៃប្រឌិតទាន់សម័យនៃគ្រប់ផលិតផល-សេវាកម្ម ប្រកបដោយឧត្តមភាព និងវិបុលភាព។

